# ការសម្ភាសរបស់លោកយាយ ស៊ីន ជា

កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ារ ខៈ អ្នកទទួលការសម្ភាសឈ្មោះស៊ីន ជា

## ការសង្ខេបប្រវត្តិរបស់លោកយាយស៊ីន ជា

លោកយាយស៊ីនជាមានអាយុ៧៦ ឆ្នាំនៅក្នុងឆ្នាំ២០២០ មានភេទស្រី មានទីលំនៅបច្ចុប្បន្ននៅភូមិទី៨ ឃុំស្រែសង្គម ស្រុកកោះញ៉ែក ខេត្តមណ្ឌលគិរី។

កៈ
ចឹងជាដំបូងខ្ញុំអរគុណច្រើនយាយដែរបានអោយខ្ញុំពិភាក្សាជាមួយយាយទាក់ទងពីប្រវត្តិរបស់យាយ
ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយជាពិសេសយាយទុកអោយកូនចៅៗរបស់យាយបានស្គាល់ហ្នឹងបានដឹង ពីប្រវត្តិរបស់យាយដែរយាយបានរៀបរាប់អោយចៅបានស្តាប់
ចឹងយាយយល់ព្រមដើម្បីអោយចៅដាក់ការសម្ភាសទាំងអស់ហ្នឹងទតក្នុងវេបសាយសាលាទេយាយ?

ខៈ ចាំ!

កៈ បាទយាយចឹសំរាប់ចៅជាអ្នកសម្ភាសយាយចៅមានឈ្មោះថាជាង ស៊ីអ៊ារ
ហើយថ្ងៃខែដែរចៅសម្ភាសយាយគឺនៅថ្ងៃទី១៣ខែ៨ឆ្នាំ២០២០
ហើយសំរាប់អើការសម្ភាសទាំងអស់នេះគឺធ្វើឡើងនៅភូមិហ្នឹងភូមិទី៨ហេសយាយហេស?

ខៈ ហ្នឹងហើយហ្នឹង!

កៈ អ៊្ហូប៉ុន្តែសង្កាត់ស្រែអើឃុំស្រែសង្គម?

ខៈ ឃុំស្រែសង្គម។

កៈ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគិរី?

ខៈ ខេត្តមណ្ឌលគិរី។

កៈ បាទយាយចឹងសំរាប់យាយឈ្មោះពេញរបស់យាយទាំងត្រកូលឈ្មោះអីគេយាយ?

ខ៖ ឈ្មោះស៊ីន ជា។

ក៖ ស៊ីន ជាណេះយាយណេះ?

ខ៖ ចាំ!

ក៖ ចុះយាយមានឈ្មោះហៅក្រៅអត់យាយ?

ខ៖ អត់មានទេ។

ក៖ ចឹងយាយមានឈ្មោះតែមួយហ្នឹងទេណេះយាយណេះ?

ខ៖ ចាំ!

ក៖ អូ៎ចុះកាលពីក្មេងយាយធ្លាប់មាននរណាគេហៅឈ្មោះយាយអីផ្សេងអត់យាយ?

ខ៖ អត់ទេ។

ក៖ អូ៎បាទយាយចុះសំរាប់យាយសព្វថ្ងៃយាយអាយុប៉ុន្មានយាយ?

ខ៖ អាយុចិតសិបប្រាំមួយ។

ក៖ យាយអាយុចិតសិបប្រាំមួយហោសយាយហោស?

ខ៖ ចាំ!

ក៖ អូ៎បាទយាយចុះយាយកើតនៅថ្ងៃខែឆ្នាំណាយាយចាំអត់?

ខ៖ ខ្ញុំកើតឆ្នាំរកា។

ក៖ ឆ្នាំរកាប៉ុន្តែឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានយាយចាំអត់?

ខ៖ មិនដឹងមិនចាំទេ។

ក៖ អូ៎យូរហើយណេះយាយណេះ?

ខ៖ យូរណាស់។

ក៖ អូ៎!

ខ៖ តាំងពីខ្ញុំនៅក្មេងៗអាយុប្រហែលបួនដប់អាយុដប់បួនដប់ប្រាំម្ភៃណោះហោស!

ក៖ បាទយាយបាទចុះយាយគិតថាទីកន្លែងដែរយាយកើតយាយកើតនៅណាយាយ?

ខ៖ កើតនៅស្រុកហោស!

កៈ ស្រុកនៅណាដែរនៅព្រៃវែងណេះ?

ខៈ ព្រៃវែងហោស?

កៈ ប៉ុន្តែភូមិ...?

ខៈ ស្រុកពាមរ។

កៈ ភូមិអីគេយាយ?

ខៈ ភូមិចំបក់ប្រាំង។

កៈ ភូមិចំបក់ ស្រុកពាមរ?

ខៈ ស្រុកពាមរ ខេត្តព្រៃវែង។

កៈ ខេត្តព្រៃវែងបាទយាយចុះយាយមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់យាយ?

ខៈ មានតែពីរនាក់ទេប៉ុន្តែប្អូនខ្ញុំអាពតគេយកទៅសំលាប់។

កៈ អូ៎ប្អូនរបស់យាយស្រីរឺក៏ប្រុសយាយ?

ខៈ ប្រុស។

កៈ អូ៎ប្រុសហោស?

ខៈ ចា៎!

កៈ អូ៎ចុះអើចឹងគេសំលាប់នៅពេលណាយាយប៉ុលពតមែន?

ខៈ
សំលាប់នៅអាដែងបែកអាពតប៉ុលពតអាដែងទាហ៊ានគេដេញទាំងប្រជាជនចេញពីភ្នំពេញហាស!

កៈ បាទយាយអូ៎ចឹងដាច់ប៉ុលពតហើយណេះយាយណេះ?

ខៈ ចា៎!

កៈ មុនប៉ុលពតរឺក៏ដាច់យាយ?

ខៈ មុនកូនខ្ញុំធ្វើទាហ៊ានទាហ៊ានម៉ាជំនាន់លុនណុលណុងចៅខ្ញុំអូ៎ប្អូនខ្ញុំណុង។

កៈ អូ៎!

ខៈ ជំនាន់នេះដល់បែកប៉ុលពតណុងបានគេកៀរពីភ្នំពេញមកបានមកនៅស្រុក។

ក៖ បាទយាយ!

ខ៖ បានមកនៅស្រុកបានគេចាប់ប្អូនខ្ញុំយកទៅសំលាប់ចោលទៅ។

ក៖
បាទអ៊ំបាទយាយចុះយាយគិតថាចឹងប៉ុន្តែប្អូនរបស់យាយពេលស្លាប់ហ្នឹងមានគ្រួសារនៅយាយ?

ខ៖ មានហើយកូនមួយទៀត។

ក៖អ៊ំប៉ុន្តែកូនយាយនៅណាទៅ?

ខ៖ កូនវានៅហ្នឹងខ្ញុំទៅឥឡូវវាបានកូនបីហើយ!

ក៖ អ៊ំប៉ុន្តែប្អូនយាយស្រីប្រុសយាយ?

ខ៖ ប្រុស។

ក៖ ប្រុសចុះប្រពន្ធយាយនៅណាទៅ?

ខ៖ ប្រពន្ធក៏គេយកទៅសំលាប់ដែរ។

ក៖ អ៊ំទាំងពីរនាក់ប្តីប្រពន្ធគេយកទៅសំលាប់ទាំងអស់ហោស?

ខ៖ ចាំ!

ក៖
អ៊ំបាទយាយចុះយាយគិតថាអើចឹងយាយធ្លាប់មានអនុស្សាវរីយ៍ជាមួយប្អូនអត់យាយពីមុនហាស?

ខ៖ មានប្អូនខ្ញុំមានតែពីរនាក់ណុងវាទៅធ្វើទាហ៊ានគេចាប់យកទៅធ្វើទាហ៊ានទៅ
អើខ្ញុំនៅតែម្នាក់ខ្ញុំទៅម៉ែជាមួយម៉ែខ្ញុំ។

ក៖ អ៊ំបាទយាយចុះយាយគិតថាចឹងឪពុកយាយឈ្មោះអីគេយាយ?

ខ៖ ឈ្មោះអឌឹម។

ក៖ ឈ្មោះអីគេឌឹម?

ខ៖ ស៊ីន ឌឹម។

ក៖ ស៊ីន ឌឹមណោះយាយណោះ?

ខ៖ ចាំ!

ក៖ អ៎ូចុះអើគាត់ស្លាប់យូរហើយណោះយាយណោះ?

ខ៖ ស្លាប់យូរដែរហើយទើបស្លាប់ណុងបែកអាពតហើយបានគាត់ស្លាប់។

ក៖ អ៎ូចឹងមានន័យថាគាត់ស្លាប់ក្រោយប្អូនរបស់យាយទៀត?

ខ៖ ស្លាប់ក្រោយប្អូនខ្ញុំគេយកទៅសំលាប់ណុងតាំងពីអាពតម៉ង។

ក៖ ប៉ុន្តែកាលឪពុកយាយស្លាប់ណុងអាយុប៉ុន្មានយាយ?

ខ៖ ឪពុកខ្ញុំស្លាប់ណុងគាត់អាយុប្រហែលចិតហើយ!

ក៖ អ៎ូចិត?

ខ៖ យូរដែរហើយ!

ក៖ បាទបើទាល់តឡូវប្រហែលជាជាងមួយរយឆ្នាំហើយណោះយាយណោះ?

ខ៖ គាត់យូរដែរហើយខ្ញុំកូនក្មេងផងទំរាំតែអាយុខ្ញុំចិតជាងដែរ។

ក៖ អ៎ូចឹងមានន័យថាគាត់យូរដែរ?

ខ៖ ចាំ!

ក៖ ប៉ុន្តែម្តាយរបស់យាយវិញឈ្មោះអីគេយាយ?

ខ៖ ឈ្មោះចាន់ ស៊ឹម។

ក៖ ចាន់ ស៊ឹមចុះអើគាត់ស្លាប់ពេលណាយាយ?

ខ៖
ស្លាប់បែកអាពតហើយគាត់រត់ទៅអាពតពេលមកវិញទៅគាត់ឈឺគាត់ធ្លាក់ពីលើផ្ទះគេដេញអោយគាត់ចុះគេដេញអោយគាត់ចុះហើយគាត់ចុះមកធ្លាក់បែកមុខបែកមាត់អស់។

ក៖ អ៎ូបាទយាយចុះអើឪពុករបស់យាយកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជិវិតចិញ្ចឹមក្រុមគ្រួសារចិញ្ចឹមកូនចៅយាយ?

ខ៖ គាត់គ្មានគាត់ធ្វើតែស្រែគ្មានធ្វើអីទេរកអីទេ។

ក៖ អ៎ូ!

ខ៖ មានតិចតួចអីគាត់ហូបមាត់គាត់ណុងហាស!

ក៖ បាទយាយ!

ខ៖ ខ្ញុំបែកមកនៅអ៊ីស្រុកអីណេះគាត់នៅស្រុកស្រែអីស្រែណេះ។

ក៖ បាទយាយអ៊ូចឹងមានន័យថាប៉ុន្តែគាត់ចេះរកត្រីរកអីដែរណេះយាយណេះ?

ខ៖ ចាំគាត់រកត្រីណុងលួចរកត្រីយប់ៗទេលោកគ្រូអើយ!

ក៖ អ៊ូ!

ខ៖ ពិបាកគេ។

ក៖
បាទយាយចុះអើចឹងឪពុករបស់យាយហ្នឹងគាត់រកអាពេលដែរគាត់មុនលុនណុលណុង
ណេះយាយណេះ?

ខ៖
ចាំមុនលុនណុលប៉ុន្តែខ្ញុំហ្នឹងបានដល់នេះខ្ញុំបែកខ្ញុំរត់មកនៅខាងប្ដីខ្ញុំដល់ស្រុកខេត្តស្រុកបា
ភ្នំហេស!

ក៖ បាទយាយ!

ខ៖ ខ្ញុំមកនៅជាមួយប្ដីខ្ញុំតាំងមកដល់នេះអាលុនណុលណុងវាទំលាក់គ្រាប់បែក។

ក៖ អ៊ូ!

ខ៖ វាបាញ់មកខ្ញុំរត់កូនខ្ញុំអាមានប្រពន្ធណុងវានៅក្នុងពោះ។

ក៖ អ៊ូចឹងមានន័យថាពូពេលណុងនៅក្នុងពោះហោស?

ខ៖
ចាំនៅក្នុងពោះទេអាលុនណុលវាទំលាក់អាគ្រាប់បំប៊ីអីខ្ញុំរត់ៗដោះក្រវ្រចប្អូនថ្លៃខ្ញុំវាដោះខោ
ដោះអាវចេញដើររត់ម៉ងបាញ់វាបាញ់ជុងៗទៅខ្ញុំចេះតែរត់ពីរនាក់ប្អូនថ្លៃចោលកង់មួយម្នាក់
ទៅកាលណុង។

ក៖
អ៊ូបាទយាយចុះអើយម្ដាយរបស់យាយវិញគាត់កាលពីមុនគាត់ធ្វើអីគេសំរាប់ចិញ្ចឹមចិញ្ចឹមកូ
នចៅយាយ?

ខ៖ វាគាត់ធ្វើអីធ្វើប្រាំងធ្វើអីហើយដូចថាធ្វើផ្អកធ្វើប្រហុកចឹងលោកគ្រូ។

កៈ បាទយាយ!

ខៈ
ធ្វើផ្អកធ្វើប្រហុកទៅដូរយកមកអោយកូនស៊ីទៅខ្ញុំក៏នៅតូចប្អូនក៏អាហ្នឹងវានៅតូចដែរកូនខ្ញុំហ្នឹងវាទើបបួនឆ្នាំណុង។

កៈ អ៊ំបាទយាយចុះយាយគិតថាឪពុកម្ដាយយាយស្លូតរឺក៏កាចយាយ?

ខៈ អត់កាចទេម៉ែខ្ញុំស្លូតណាស់មិនដែរអោយកូនធ្វើអីទេ។

កៈ អ៊ំចឹងហោស?

ខៈ
គាត់ឃើញកូនកំព្រីកំព្រាណាស់កំព្រីកំព្រាអត់មានអ្នកណារកគាត់រកស៊ីចិញ្ចឹមតែខ្លួនគាត់ចិញ្ចឹមចៅចិញ្ចឹមកូនហ្នឹង!

កៈ
អ៊ំបាទយាយចុះយាយគិតថាយាយធ្លាប់មានចាំសាច់រឿងកាលឪពុកម្ដាយយាយនៅរស់យាយធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់អត់យាយ?

ខៈ ធ្វើអីទេទៅធ្វើតែប្រាំងហើយកាប់អូសកាប់ព្រៃអីទូលលក់ណុងគ្មានធ្វើអីទេ
រកស្រូវរកអង្ករពីស្រុកលើយកមកហូបអីស្រុកក្រោមហ្នឹងទៅមានអីចេះតែហូបហ្នឹងទៅគាត់ដូរផ្អកដូរប្រហុកយកមកចិញ្ចឹមចៅ ចិញ្ចឹមកូនទៅ។

កៈ អ៊ំទៅជាមួយយាយអីទៅធ្វើស្រែធ្វើអីហាសណោះយាយណោះ?

ខៈ ចាំខ្ញុំធ្វើតែស្រូវប្រាំងទេទេស្រែលើអត់មានទេ។

កៈ
អ៊ំបាទចុះយាយគិតថាចឹងឪពុករបស់យាយកាលពីមុនគាត់បានម្ដាយរបស់យាយគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងដូចថាគាត់ធ្លាប់ធ្វើការងារអីគេខ្លះអត់យាយទៅយាយហាស?

ខៈ
ចាំគាត់ប្រាប់ថាកុំខំរកស៊ីទៅអត់ពីម៉ែទៅម៉ែឪគ្មាននៅចិញ្ចឹមកូនទៀតទេម៉ែបែកបានតែពីរបីខែម៉ែស្លាប់ទៀត។

កៈ បាទយាយអ៊ំចុះម្ដាយយាយវិញគាត់ធ្លាប់ប្រាប់អីអត់?

ខ៖
ម្ដាយខ្ញុំគាត់រកស៊ីតែពីរនាក់ម៉ែកូនណុងមានអីទេតែខ្ញុំហើយហ្នឹងគាត់ហ្នឹងហាសអត់ទាន់មានកូនខ្ញុំទេខ្ញុំអត់ទាន់មានប្ដីទេកាលណុង។

ក៖ បាទយាយអ៊ំចុះអើចឹងយាយតាខាងឪពុកយាយស្គាល់ឈ្មោះគាត់អត់យាយ?

ខ៖ យាយតាខាងឪពុកហោស?

ក៖ បាទ!

ខ៖ ឈ្មោះតាស៊ីន យាយតូច។

ក៖ យាយតាខាងម្ដាយ?

ខ៖ ខាងម្ដាយចាន់ ស៊ឹម ហើយចាន់យី។

ក៖ ចាន់ យី?

ខ៖ ចា៎!

ក៖ តាចាន់ យាយយី?

ខ៖ ចា៎!

ក៖
អ៊ំចុះអើយាយតាខាងឪពុកហ្នឹងយាយតាខាងម្ដាយគាត់អ្នកនៅស្រុកណានៅស្រុកព្រៃវែងហ្នឹងដែរមែន?

ខ៖ ស្រុកបាភ្នំខេត្តព្រៃវែងដូចតែគ្នាហ្នឹងប៉ុនអើគាត់នៅស្រែលើ។

ក៖ អ៊ំ!

ខ៖
ស្រុកបាភ្នំអីណោះហើយខ្ញុំខ្ញុំនៅអីស្រុកចុងភូមិចំបក់ប្រាំងណោះស្រុកពាមរខេត្តព្រៃវែង។

ក៖ អ៊ំចឹងពួកគាត់ទាំងអស់គ្នាអ្នកខេត្តព្រៃវែងទាំងអស់ហោស?

ខ៖ ចា៎!

ក៖ អ៊ំ!

ខ៖
ខេត្តព្រៃវែងដូចគ្នាប៉ុន្តែដល់នេះគាត់បែកម៉ែខ្ញុំគាត់បែកម៉ែខ្ញុំគាត់មកនៅស្រុកបាភ្នំអីណេះ ស្រុកភូមិបឹងព្រះ។

ក៖ អ៎ូបាទយាយចុះយាយគិតថាអើចឹងយាយមករស់នៅកោះញ៉ែកហ្នឹងយូរនៅយាយ?

ខ៖
ខ្ញុំមកជិតដប់ឆ្នាំហើយមកនៅជាមួយកូនខ្ញុំប៉ុន្តែខ្ញុំទៅស្រុកវិញទៅស្រុកវិញវាទៅហៅខ្ញុំមកវិញទៅមកបានប្រហែលបីបួនឆ្នាំទៀតណុងហោស!

ក៖
ចុះពីមុនយាយនៅកោះញ៉ែកណុងយាយយាយនៅណាយាយនៅព្រៃវែងនៅពាមរហោស យាយ?

ខ៖ និយាយខ្ញុំនៅស្រុកពាមរខេត្តព្រៃវែងហ្នឹងទេ។

ក៖ អ៎ូប៉ុន្តែកាលពីមុនយាយមកហ្នឹងយាយធ្វើអីគេនៅណុងយាយ?

ខ៖ ខ្ញុំនៅណុងខ្ញុំនៅម្នាក់ឯង!

ក៖ អ៎ូចុះកូនចៅយាយនៅណុង?

ខ៖ ខ្ញុំអត់មានកូនចៅទេកូនទើបមានម៉ាអាហ្នឹងមកបែកអាពតទេ។

ក៖ អ៎ូ!

ខ៖
ហើយខ្ញុំរត់អូយរត់ៗយួរខោអាវមួយកន្ត្រកចឹងទៅកូននៅក្នុងពោះចុកផងអីផងកាលណុង ថាចុកម៉ងលោកគ្រូអើយវេទនាណាស់ខ្ញុំមក។

ក៖ អ៎ូចុះយាយចឹងយាយកាលពីមុនយាយមកហ្នឹងយាយនៅពាមរយាយនៅម្នាក់ឯង?

ខ៖ នៅម្នាក់ឯងប៉ុនកូនទៅយកមកពីរបីឆ្នាំហ្នឹងហាស!

ក៖ អ៎ូយើងមានផ្ទះមានអីនៅហ្នឹងមានដីស្រែនៅណុងហោសយាយហោស?

ខ៖ មានដីស្រែដល់ខ្ញុំមកខ្ញុំលក់ទៅខ្ញុំយកលុយមកគ្រាន់មើលខ្លួន។

ក៖ អ៎ូ!

ខ៖ ទៅកាលណុងមានអី។

កៈ បាទយាយបាទ!

ខៈ
ហើយប្អូនខ្ញុំគេយកទៅសំលាប់ហើយនៅតែខ្ញុំមួយហ្នឹងនៅម្នាក់ឯងនៅញាតិជិតខាងគេចេះតែអោយនេះអោយនោះរហូតទៅទៅវត្តទៅវាអីជាមួយគេទៅ។

កៈ អូ៎ដល់ពេលយើងមកនៅជាមួយកូនទៅរៀងស្រួលជាងមុនណេះយាយណេះ?

ខៈ ចាំបានខ្ញុំមកនៅជាមួយកូនហ្នឹង!

កៈ
អូ៎យាយចុះយាយគិតថាចឹងសំរាប់យាយមានកូនចៅចៅទួតណាដែរទៅរស់នៅខេត្តផ្សេងអត់យាយ?

ខៈ ចៅទួតគ្មានទេមានតែចៅកូនហ្នឹងហាសផ្ទះហ្នឹង!

កៈ ដែរនៅកោះញែកមណ្ឌលគិរីហ្នឹង?

ខៈ ចាំ!

កៈ
ចុះអត់មាននរណាគេចៅណាទៅធ្វើការនៅថៃនៅវៀតណាមអីអត់មានទេណេះយាយណេះ?

ខៈ
អត់មានទេកូនខ្ញុំអត់មានទេចៅខ្ញុំសុទ្ធតែទៅស៊ីឈ្នួលគេនៅភ្នំពេញហើយហ្នឹងនៅហ្នឹងទេ។

កៈ អូ៎ចឹងមាននៅមណ្ឌលគិរីហ្នឹងហើយនៅភ្នំពេញ?

ខៈ ចាំ!

កៈ ទៅធ្វើការអោយគេណេះយាយណេះ?

ខៈ ចាំ!

កៈ អូ៎បាទយាយចុះយាយគិតថា...?

ខៈ គ្រាន់ទៅស៊ីឈ្នួលគេបីនាក់ហោស!

កៈ អូ៎!

ខៈ ចៅខ្ញុំ។

កៈ នៅភ្នំពេញហោសយាយ?

ខៈ នៅហ្នឹងទៅស៊ីវានៅភ្នំពេញម្នាក់។

កៈ នៅពីរនាក់?

ខៈ ហើយថែមពីរនាក់នៅភ្នំពេញមួយទៀតនៅនេះ។

កៈ អូ៎!

ខៈ នៅ..។

កៈ ចុះយាយគិតថាចឹងប្ដីរបស់យាយឈ្មោះអីគេយាយ?

ខៈ ឈ្មោះអ៊ុត។

កៈ ឈ្មោះអីគេអ៊ុតយាយ?

ខៈ ម៉ម អ៊ុត។

កៈ ចុះគាត់នៅណាទៅឥឡូវយាយ?

ខៈ គាត់គេសំលាប់តាំងពីចិតប្រាំពីរម៉េស។

កៈ អូ៎គេសំលាប់ប៉ុលពតដែរណេះយាយ?

ខៈ ចា៎!

កៈ អូ៎ហេតុអីបានគេសំលាប់គាត់យាយ?

ខៈ
វាសំលាប់ដឹងអីគាត់ទៅធ្វើការខ្ញុំនៅអីផ្ទះគេអត់មានប្រាប់អោយដឹងផងស្រាប់តែគេអ្នកទៅធ្វើការក្បែរៗណុងគេហៅទៅដែរជីកដែរកាប់ដីអីប្រឡាយអីចឹងហាស!

កៈ បាទយាយ!

ខៈ បានគេថាប្ដីខ្ញុំស្លាប់ហើយកុំយំកុំស្រែកប្រយ័ត្នសំលាប់ដែរ។

កៈ អូ៎បាទយាយ!

ខៈ
ហើយខ្ញុំអត់មានបានសំរកទឹកភ្នែកជាមួយដីអីបានឃើញមុខឃើញអីអត់ទេទើបតែឥឡូវ។

កៈ អូ៎ចឹងយើងបាត់គាត់តាំងពីណុងមករហូត?

ខ៖ ចាំសំលាប់។

ក៖ ប៉ុន្តែគាត់ធ្វើការនៅប៉ុលពតហ្នឹងធ្វើការអីគេយាយ?

ខ៖ កាលណុងគេអោយគាត់ធ្វើឈ្លប។

ក៖ អូ!

ខ៖ ដោយសារនៅក្នុងភូមិឋានចឹងហាសដល់នេះគេអោយគាត់មើលអាដែងអ្នកលើកដីលើកប្រឡាយអីចឹងហាស!

ក៖ អូបាទយាយរួចចុះកើតអីបានគេសំលាប់គាត់ទៅយាយ?

ខ៖ ខ្ញុំមួយខែពីរខែមិនទាន់មកផ្ទះផង។

ក៖ អូ!

ខ៖ យកទៅសំលាប់ចោលប្តីខ្ញុំគ្មានបានដឹងឃើញមុខប្តីម៉េចទេ។

ក៖ អូបាទយាយប៉ុន្តែយាយនៅឆ្ងាយពីតាណោះយាយជំនាន់ប៉ុលពតណោះយាយណោះ?

ខ៖ ចាំ!

ក៖ អូបាទប៉ុន្តែពីមុនហ្នឹងប៉ុលពតហ្នឹងតាធ្វើអីគេសំរាប់ចិញ្ចឹមយាយចិញ្ចឹមកូនចៅយាយ?
ខ៖ តាណាតា...។

ក៖ ប្តីរបស់យាយ?

ខ៖ គាត់រកទៅរកស៊ីឈ្នួលទិញឥវ៉ាន់ទិញអីលក់ចឹងពីភូមិស្រុកពាមរទៅទៅដល់ស្រុកយួនហោស!

ក៖ អូបាទយាយចុះយាយគិតថាយាយមានកូនប៉ុន្មាននាក់យាយ?

ខ៖ ខ្ញុំកូនខ្ញុំមានខ្ញុំសុំគេកូនមួយកូនខ្ញុំបង្កើតមួយនៅហ្នឹងហាស!

ក៖ អូចឹងយាយមានកូនពីរនាក់ហោសយាយណោះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែអើកូនរបស់យាយមួយទៀតហ្នឹងប្អូនរឺមួយក៏បង?

ខ៖ អាវាហ្នឹងបងអានោះអាហ្នឹងប្អូន។

ក៖ អ៊ំចឹងយាយមកនៅជាមួយពូប្អូនទេណេះ?

ខ៖ ចា៎!

ក៖ អើចុះកូនបងគាត់ធ្វើអីគេយាយ?

ខ៖ កូនបងដើររកស៊ីតែឈ្នួលគេ។

ក៖ ធ្វើសំណង់?

ខ៖
ធ្វើសំណង់ធ្វើអីហ្នឹងទើបតែទៅផ្ទះបានប្រហែលជាបួនដប់ថ្ងៃកន្លះខែទេទៅពីភ្នំពេញទៅហ្នឹងទទួលស្រុកគេចឹងទៅ។

ក៖ អ៊ំពីមុនគាត់នៅណាយាយ?

ខ៖ កូនខ្ញុំហោស!

ក៖ បាទកូនបង?

ខ៖
កូនបងវានៅជាមួយខ្ញុំទាល់តឡូវហ្នឹងវាមានប្រពន្ធគេអោយវាធ្វើទាហ៊ានដល់នេះវាមកនៅស្វាយឧន្ទរហោស!

ក៖ អ៊ំគាត់នៅខាងព្រៃវែងដែរហោសយាយណេះ?

ខ៖ ចា៎!

ក៖ ប៉ុន្តែតឡូវគាត់នៅព្រៃវែងហ្នឹងយាយ?

ខ៖ នៅព្រៃវែងហ្នឹង!

ក៖ នៅស្វាយឧន្ទរ?

ខ៖ នៅស្វាយឧន្ទរហ្នឹង!

ក៖ អ៊ំប៉ុន្តែគាត់ហ្នឹងមានកូនចៅតទៀតហាសណេះយាយណេះ?

ខ៖ គាត់គ្រាន់វាកូនបីស្រីពីរប្រុសមួយ។

ក៖ អ្ហំប៉ុន្តែយាយមានចៅទួតនៅយាយ?

ខ៖ ចៅទួតខ្ញុំមានដល់បីនាក់ហើយ!

ក៖ អូ៎ចុះអើពូដែរនៅជាមួយយាយរាល់ថ្ងៃគាត់ធ្វើអីគេទៅយាយ?

ខ៖
គាត់ធ្វើតែស្រែហើយមើលគោវាឈឺវាគ្រុនពោះវៀតហើយគេពោះវៀនទៅគ្មានអោយធ្វើការអីទេ គ្រាន់តែអោយទៅមើលគោមើលអីហ្នឹង!

ក៖ អូ៎!

ខ៖ វាពោះវៀនដុះខ្នែង។

ក៖ ពោះវៀនដុះខ្នែងហោស?

ខ៖ វាពោះវៀនដុះខ្នែង។

ក៖ ចឹងយើងត្រូវការតមហាសណោះយាយណោះ?

ខ៖ អើ!

ក៖ អត់អោយធ្វើការធ្ងន់?

ខ៖
មានដែរអោយធ្វើអីអោយដេញតែគោអោយមើលទៅតិចតួចផ្ទះមានបានធ្វើអីទេឈឺអ្វើមិនបាន។

ក៖
អូ៎បាទយាយចុះយាយគិតថាចឹងយាយការជាមួយតាហ្នឹងអស់រយះពេលប៉ុន្មានឆ្នាំហើយយាយ?

ខ៖ ខ្ញុំការយូរដែរហើយតាំងពីការបានប្រាំពីរឆ្នាំបានខ្ញុំមានកូនក្នុងមួយហាហ្នឹង!

ក៖ អូ៎ប៉ុន្តែយាយការហ្នឹងយាយអាយុប៉ុន្មានយាយ?

ខ៖ ខ្ញុំការអាយុសាមបីអូ៎ម្ភៃបីទេ។

ក៖ ម្ភៃបីដល់ពេលឥឡូវយាយអាយុចិតសិប?

ខ៖ ចិតប្រាំមួយ។

ក៖ ចិតប្រាំមួយណោះយាយណោះ?

ខ៖ ចាំ!

កៈ ចឹងយាយការអស់ជាងហាសិបឆ្នាំ?

ខៈ ចា៎!

កៈ
អ៊ូបាទយាយចុះយាយគិតថានៅពេលដែរយាយការជាមួយតាហ្នឹងយាយជាអ្នកចិត្តចង់ដោយខ្លួនឯង រឺមួយក៏មានការឪពុកម្ដាយជាអ្នក..?

ខៈ ឪពុកម្ដាយគេមកស្ដីដល់ស្រុកយើងហ្នឹងហាសគេនៅដល់ស្រុកស្រែតើ!

កៈ
អ៊ូបាទយាយចុះកាលពីមុនយើងការហ្នឹងយើងស្គាល់គ្នាពីមុនអត់យាយស្គាល់ជាមួយតា?

ខៈ
ស្គាល់ដែរគាត់មកវាមកលេងស្រុកខ្ញុំជាមួយបងវាជីដូនមួយបង្កើតគេចេះតែមកលេងទៅទៅផ្ទះវិញទៅមកពីរបីយប់បងជាមួយជីដូនមួយនៅក្បែរខ្ញុំហ្នឹង!

កៈ
អ៊ូបាទយាយប៉ុន្តែកាលជំនាន់យាយការហ្នឹងមានជាថ្លៃបណ្ណាការគេហៅថ្លៃទឹកដោះហាសមានអត់យាយ?

ខៈ មាន។

កៈ
ប៉ុន្តែជំនាន់យាយការហ្នឹងគេមានលុយហើយណោះយាយចាយលុយហើយណោះយាយណោះ?

ខៈ ចាយនៅចាយតើ!

កៈ អ៊ូ!

ខៈ
ដល់តែខ្ញុំការហើយបានគេអត់មានចងដៃទេគេមានប្រាក់ក្ដុកអីមួយរយេកាលយាយតាពីដើមគេចងមួយរៀល
តែមួយរៀលណុងអោយតែមួយរៀលគួចដៃមួយរៀលលុយណុងគេអត់ចាយណុង
ប៉ុនគេសំរាប់ចុះៗអង្ករកូនក្មេងអីហ្នឹងហាស!

កៈ បាទយាយបាទ!

ខ៖ ព្រោះលុយអត់មានទេកាលណុងអីស្រុកស្រែណុង។

ក៖ លុយខ្មែរ..?

ខ៖ កាលណុងអត់មានទេ។

ក៖ អូ៎បាទយាយប៉ុន្តែគេចាយកាក់ចាយអីចឹងហាសណេះយាយ?

ខ៖ ហ្នឹងហើយកាលណុង។

ក៖ ប៉ុន្តែកាលយើងការហ្នឹងនៅលុនណុលណេះយាយណេះ?

ខ៖ នៅលុនណុលនៅលុនណុលកាលណុងលុនណុលក៏នៅសម្ដេចតាក៏នៅដែរ។

ក៖
អូ៎ប៉ុន្តែកាលយើងការហ្នឹងការខុសពីយើងការឥឡូវមួយក៏ម៉េចយាយយាយអាចប្រាប់ចៅបានទេ?

ខ៖ ការមានអីការមានភ្លេងមានភ្លាត់អីដូចតែគ្នា។

ក៖ អូ៎បាទយាយប៉ុន្តែគេមានសែនអីដូចតែឥឡូវចឹងណេះយាយណេះ?

ខ៖
អត់ទេគ្មានទេខ្ញុំម៉ែខ្ញុំមានតែកូនខ្ញុំមានតែខ្ញុំមួយហើយបានមកមានអាប្អូនមួយទៀតឆ្នាំកោរ។

ក៖ បាទយាយ!

ខ៖ ប្អូនខ្ញុំហើយពីរបីឆ្នាំទេអាដែងគេយកទៅសំលាប់ណុងធ្វើទាហ៊ានណុង។

ក៖ បាទយាយបាទ!

ខ៖
រត់គ្រាន់រត់ពីភ្នំពេញទៅដល់ផ្ទះខំរត់មករកបងថាបងនៅម្នាក់ឯងមកជាងមួយខែបានរត់ដល់ផ្ទះ។

ក៖ អូ៎!

ខ៖ ទៅតាមកោះធំហោស!

ក៖ អូ៎បាទយាយចុះយាយគិតថាយាយធ្លាប់បានរៀនខ្មែរពីមុនអត់យាយ?

ខ៖ ខ្ញុំចេះដែរប៉ុនឥឡូវខ្ញុំមើលអត់ឃើញទេអក្សរអីផិមអីក៏ខ្ញុំចេះមើលរួចទាំងអស់ហ្នឹង!

កៈ អូ៎បាទយាយប៉ុន្តែដូចជាយាយរៀនបានថ្នាក់ទីប៉ុន្មានដែរយាយ?

ខៈ ខ្ញុំរៀនថ្នាក់ទីបីហ្នឹង!

កៈ ទីបីណោះយាយណោះ?

ខៈ ចា៎!

កៈ អូ៎ប៉ុន្តែពេលណុងគេអោយយាយរៀនបារាំងរៀនអីអត់យាយ?

ខៈ អត់ទេ។

កៈ យើងរៀនថ្នាក់តិចពេកណោះយាយណោះ?

ខៈ ចា៎!

កៈ អូ៎តែកាលយាយរៀនយាយរៀននៅណាយាយ?

ខៈ រៀនអីភូមិតាមស្រុកណុងដែរភូមិស្រុកភូមិចំបក់ប្រាំងស្រុកពាមរដែរហ្នឹង!

កៈ
អូ៎បាទយាយចុះកាលយាយរៀនហ្នឹងយាយធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់យាយ?

ខៈ អត់មានទេជំនាន់ណុងវានៅដូចថាគេអោយអាពតបង្រៀនចឹងហាស!

កៈ បាទយាយ!

ខៈ មិនទាន់មានមិត្តភក្តិអីទេបងខ្ញុំអើប្អូនខ្ញុំធ្វើលោកបួសបង្រៀន។

កៈ អូ៎បាទយាយប្អូនរបស់យាយហោស?

ខៈ ប្អូនជីដូនមួយ។

កៈ អូ៎ផ្ទះនៅក្បែរគ្នាហ្នឹងគេអោយលោកសឹកទៅគេអោយបង្រៀន។

កៈ អូ៎ចឹងមានន័យថាប្អូនជីដូនមួយរបស់យាយជាអ្នកបង្រៀនវិញ?

ខៈ ចា៎ហើយដល់ទៅបានដល់តែបែកអាពតហ្នឹងមែនទែនបានប្អូនថ្លៃខ្ញុំហោសបង្រៀន។

កៈ អូ៎បាទយាយចុះចឹងយាយគិតថាស្រែចំការយាយធ្លាប់ធ្វើណោះយាយណោះ?

ខៈ ធ្លាប់ធ្វើ។

កៈ ភាគច្រើននៅស្រែយាយធ្វើអីគេយាយ?

ខ៖ ចាំ!

ក៖ នៅស្រែភាគច្រើនយាយធ្វើអីគេ?

ខ៖ កាលខ្ញុំនៅស្រែហ្នឹងហោស?

ក៖ បាទយាយ!

ខ៖
នៅស្រែហ្នឹងខ្ញុំមិនសូវបានធ្វើទេស្រែគេឪក្មេកម៉ែក្មេកខ្ញុំចែកអោយចឹងទៅគាត់ធ្វើអោយទុកស្រូវដាក់ជង្រុកអោយទៅ។

ក៖ អូ៎បាទយាយប៉ុន្តែកាលណុងយាយធ្វើស្រែយាយធ្វើតែម្នាក់ឯងទេណោះយាយណោះ?

ខ៖ ចាំកាលខ្ញុំនៅធ្វើជាមួយម៉ែខ្ញុំហ្នឹងបានស្រែប្រាំងហ្នឹងអាហ្នឹងពីរនាក់ម៉ែខ្ញុំ។

ក៖
អូ៎បាទយាយចុះយាយគិតថាចឹងសំរាប់ដូចជារកស៊ីលក់ដូរបើកអាជីវកម្មអីយាយធ្លាប់ធ្វើអត់យាយ?

ខ៖
ធ្លាប់លក់ដូរសព្វទាំងអស់តាំងពីត្រឡាចឃ្លោកអីទូលលក់ស្ពឺនុំចំណីអីម៉ែខ្ញុំវេចទៅខ្ញុំដើរទូលលក់ទៅ។

ក៖ អូ៎ប៉ុន្តែចំការយើងក៏មានធ្វើដែរណោះយាយណោះ?

ខ៖ មានចំការក៏មានស្រែស្រូវស្រែប្រាំងក៏មានខ្ញុំធ្វើទាំងអស់ហ្នឹង!

ក៖ អូ៎!

ខ៖
ដាំពោតដាំសណ្តែកដល់ខ្ញុំមកហ្នឹងខ្ញុំបានខ្ញុំលក់ដីអស់រលីងទៅថាមកនៅជាមួយកូនហើយទុកដីធ្វើអីនាំគេភ្លូរចុះភ្លូរឡើងវាអស់ដីដីកាលណុងគេចែកអោយម្នាក់បានតែដូចចាប់បានបួនម៉ែត្រកូនខ្ញុំគេអោយតែម្នាក់មួយម៉ែត្រទេកូនពីរនាក់គេអោយពីរម៉ែត្របានដីប្រាំមួយម៉ែត្រ។

ក៖
អូ៎បាទយាយចុះចឹងយាយគិតថាអើយាយធ្វើតែស្រែធ្វើដែរធ្វើចំការហើយហ្នឹងលក់ដូរចឹងហាសណោះយាយ?

ខ៖
ចាំហើយហ្នឹងលក់ដូរទៅផ្សារលក់ដូរចឹងទៅមកផ្ទះចឹងទៅម៉ែខ្ញុំគាត់ធ្វើនុំអោយទូលលក់ទៅ។

ក៖ អូ៎បាទយាយប៉ុន្តែយាយចេះធ្វើនុំធ្វើអីដែរយាយ?

ខ៖
ចាំខ្ញុំនុំអីវេចតែនុំចេកនុំអន្សមហែងជ្រូកអីចឹងលក់ទៅទូលលក់ទៅមួយស្របក់មកខ្វះអីភូមិខ្ញុំសុទ្ធតែមនុស្សហ្នឹង!

ក៖ សុទ្ធតែក្មេងណោះយាយ?

ខ៖ សុទ្ធតែក្មេងយួនណែនពីរជួរគ្រាន់តែយួននៅភូមិខ្ញុំ។

ក៖ អូ៎ចឹងភាគច្រើនបើយើងធ្វើហើយលក់តែមួយភ្លេតអស់ហើយណោះយាយ?

ខ៖
ចាំលក់មួយភ្លេតហ្នឹងអស់ហើយហើយប្អូនខ្ញុំអាប្រុសដែរគេយកទៅសំលាប់ណុងអាណុងដើរពពាយនាយស្រួលទាំងអស់លក់នុំដែរ។

ក៖ អូ៎ចឹងប្អូនរបស់យាយហ្នឹងយាយទៅលក់ជាមួយយាយចឹងទៅ?

ខ៖ ចាំវាដូចថាវាទៅលក់ខាងកើតហ្នឹងទៅខ្ញុំទៅលិចចឹងទៅ។

ក៖ នៅក្នុងភូមិហ្នឹង?

ខ៖ នៅក្នុងភូមិហ្នឹង!

ក៖ អូ៎បាទយាយ!

ខ៖
ហើយដល់អោយវាលែងលក់នុំទៅវាទិញនុំប៉ុងម្តងមួយរយចឹងទៅនុំប៉ុងកាលណុងមួយមួយរយរៀល។

ក៖ បាទយាយ!

ខ៖
ហើយកាលណុងវាលក់តែនុំប៉ុងហ្នឹងទៅឡើងពីមាន់រងាវម៉ោងបីម៉ោងបួនគេយកនុំប៉ុងមកភ្លឺឡើងមកដល់ផ្ទះពពាយនាយលក់នុំប៉ុងស្កូរសនុំប៉ុងស្កូរសទៅមានណាបើមានតែយាយហើយចៅពីរនាក់បើមិនរកស៊ី។

ក៖
ត្រូវយាយចុះយាយគិតថាចឹងអើបើយើងលក់ដុំលក់អីចឹងមួយថ្ងៃយើងរកបានប៉ុន្មានទៅយាយជំនាន់ណុង?

ខ៖
ទិញដំនើបហ្នឹងមិនអ្នកទិញទេដំនើបម៉ែខ្ញុំគាត់ទៅរកស្រុកស្រែហ្នឹងបានបីបួនប៉ាវចឹងទៅយកមកលក់ទៅ
លក់ទៅដកតែថ្លៃទិញឥវ៉ាន់ទិញអីសព្វចេកក៏ទិញដែរទិញតែសណ្ដែកទិញតែអីហ្នឹងស្ករដូងអីហ្នឹង!

ក៖ អូ៎បាទយាយ!

ខ៖
អត់នេះទៅលែងលក់នុំទៅម៉ែខ្ញុំក៏ទិញពោតគេពោតគ្រាប់ពោតស្ករយើងយកមកកិនៗបុកៗទៅធ្វើបោតឈូសដើរលក់។

ក៖ អូ៎បាទយាយចឹងពេលណុងយាយរកច្រើនណេះយាយណេះ?

ខ៖ ចា៎!

ក៖ អោយតែមានមុខរបររក?

ខ៖
អោយតែមានមុខរបររកភ្ញាក់ពីយប់ទៅម៉ោងបីម៉ោងបួនប្រាំងអីហ្នឹងឡើងរៀបចំទៅម៉ោងបួនអីហ្នឹងខ្ញុំម៉ែខ្ញុំចម្លងម៉ែខ្ញុំទៅលក់ទៅដល់ពេលទៅបានទៅចម្លងគាត់មកវិញចុះផ្ទះខ្ញុំខែវស្សាវាលិចទឹក។

ក៖
អូ៎បាទយាយចុះយាយគិតថាចឹងតាំងពីក្មេងរហូតមកដល់ឥឡូវយាយការងារអីគេខ្លះដែរយាយធ្លាប់ធ្វើទៅ?

ខ៖
អើតែដាំសណ្ដែកពោតអីហ្នឹងហើយដាំថ្នាំដាំអីទៅចេះតែប៉ុណ្ណឹងហើយខ្ញុំទៅរកស៊ីដល់ស្រុកយួនស្រុកអីណុងទិញឥវ៉ាន់ទិញអង្ករទិញស្អីៗយកទៅលក់ទៅ។

ក៖ អូ៎!

ខ៖ ល្ងាចព្រឹកចឹងទៅល្ងាចយប់ចឹងមកវិញហើយព្រលឹមឡើងទិញឥវ៉ាន់ចុះទៀតទៅ។

កៈ
អ៊ូបាទយាយចុះយាយគិតថាចឹងអើជីវិតរបស់យាយមានការផ្លាស់ប្តូរអីគេទៅយាយតាំងពីក្មេងរហូតមកដល់ឥឡូវ?

ខៈ
មានផ្លាស់ប្តូរអីបើគ្មានអីណារកហ្នឹងគេផងមានតែពីរនាក់យាយចាស់ម៉ែខ្ញុំគាត់ចាស់ហើយ!

កៈ បាទយាយបាទចុះយាយគិតថាកាលពីយាយនៅជាមួយឪពុកម្តាយពិបាកអត់យាយ?

ខៈ ពិបាកដែរម៉ែខ្ញុំគាត់ដាំតែពោតដាំសណ្តែកមុនតាឪគាត់។

កៈ អ៊ូ!

ខៈ ដាំតែពោតខែទុំចឹងទៅជញ្ជូនប្រហែលពីហ្នឹងជិតដល់ទីប្រាំបួនអីណោះ។

កៈ ឆ្នាយហាសណោះយាយ?

ខៈ
ជញ្ជូនមកដាក់ទូកទូកនៅចតទុកនៅកំពង់ចឹងទៅបានទូកមកដាក់ទូកទៅមកវិញឡើងដល់ផ្ទះជញ្ជូនឡើងដាក់លើផ្ទះទៀតដាក់ផ្ទះហើយហ្នឹងហើយអស់ទៅបួនដប់ទូកចឹងទៅបានហាលបកហាលបកហាលបានប្រលះចេះតែហាលៗទៅ។

កៈ អ៊ូបាទយាយចុះអើនៅពេលដែរយាយមានគ្រួសារហើយម៉េចទៅយាយ?

ខៈ មានគ្រួសារហើយខ្ញុំទៅរកស៊ីដល់ស្រុកក្រោមហោសដល់យួនទល់ដែនយួនហ្នឹងទៅ។

កៈ អ៊ូបាទយាយ!

ខៈ
មិនដែរធ្វើអីទេកាលទៅចាំមើលកាលខ្ញុំធ្វើប្រាំងទៅចាំទាំងស្រូវទាំងយប់ទាំងថ្ងៃពីរនាក់កូនខ្ញុំមកហ្នឹងហាស!

កៈ អ៊ូ!

ខៈ វានៅប្រហែលប៉ុនកូនមិញហ្នឹង!

កៈ យ៉យបិទសំលេងតិច។

ខៈ បាយទឹកយោង។

កៈ អ៊ូ!

ខ៖ ពីរនាក់កូនខ្ញុំហ្នឹង!

ក៖ អូ៎!

ខ៖
គេមានរហាត់ផ្ទះខ្ញុំមានមនុស្សប្រុសណាមានអត់មានរហាត់មានអីទេយោងប៉ោតហ្នឹងទៅអាធំហោសអាបងវាហ្នឹងអាណុងវាតូចវាស្គមបៅទឹកដោះគោ។

ក៖ បាទយាយ!

ខ៖
ដល់អាបាចចឹងទៅវាហាត់វាហាត់ទៅវាយំអានេះវាចប់បាចអោយបានមួយរយយោងបានអោយឈប់ ហើយអានោះវាហាត់វាវាហាត់វាចេះតែយំ។

ក៖ អត់មានកំលាំង?

ខ៖ អត់មានកំលាំងទេស្គម។

ក៖ អូ៎!

ខ៖ បាចសុទ្ធតែដាក់វេនគ្នា។

ក៖ សុទ្ធតែដាក់វេនគ្នាហោសមីង?

ខ៖ ចាំដាក់វេនបើវាអស់ទឹកចឹងមួយរយពីររយប៉ោតចឹងបានឈប់ម្តង
ពីររយប៉ោតចឹងឈប់ម្តង។

ក៖ អូ៎!

ខ៖
តែចឹងបានអាណុងវាយំថាបងឯងបាចៗវាហាត់ជិតងាប់ហើយដល់នេះម៉ែខ្ញុំក៏ទៅផ្លាស់ទៅអោយវាឈប់ម្តងទៅ។

ក៖ អូ៎!

ខ៖ លើកឬស្សីពីរចបអោយលើកតែមួយទេ។

ក៖ អូ៎បាទ!

ខ៖ អាហ្នឹងយើងអត់មនុស្សហាស!

ក៖ បាទមីងបាទ!

ខៈ ពិបាកហាសស្រែវេទនាហាសអាទិត្យអើយ!

កៈ បាទមីង!

ខៈ គ្មានម៉ាស៊ីនគ្មានអីទេវេទនាណាស់កំលាំងមនុស្សមែន។

កៈ ធ្វើដោយកំលាំងម៉ងហោសយាយ?

ខៈ
គេអោយស្រូវវាផ្លែហើយគោយន្តវាលេងមកពប់រយចឹងទៅទៅដេកចាំពីរនាក់កូនខ្ញុំអាហ្នឹង
ហាសទៅនៅក្បែរបឹងណាភេអើយយកទៅណាអស់ទេខ្លាចភេហ្នឹងទៀត។

កៈ សត្វភេហីយាយ?

ខៈ ចាំភេតាមដល់នេះដល់។

កៈ អូ៎!

ខៈ
ដល់ខ្ញុំខ្លាចពេកមានអាក្មួយខ្ញុំក្មួយវាធ្វើស្រែក្របែលដៃវាចេះតែដើរមកមុនខ្ញុំខ្ញុំទៅដល់ខ្ញុំខ្លា
ចពេក ខ្លាចពេកដេកទៅធ្វើរោងក្បែរវាទៅ។

កៈ អូ៎បាទយាយ!

ខៈ អើថ្ងៃចាំចាបយប់ចាំគោ។

កៈ ថ្ងៃចាំចាបយប់ចាំគោ?

ខៈ ចាំហ្នឹងវាវេទនាណាស់លោកគ្រូអើយលោកគ្រូ។

កៈ អូ៎!

ខៈ រួចសុទ្ធតែចាបកាលណុង។

កៈ
អូ៎បាទចុះយាយគិតថាចឹងពេលពីមុនយាយមានប្ដីនៅជាមួយឪពុកម្ដាយរឺមួយក៏នៅជាមួយ
ឪពុកម្ដាយនរណាគេហាត់ពិបាកជាងយាយ?

ខៈ
មានហាត់តែប្ដីខ្ញុំអត់អោយហាត់មានអត់ហាត់ទេគ្រាន់តែថារកស៊ីតែម្នាក់ឯងទៅខ្ញុំនៅផ្ទះខ្ញុំធ្វើ

ផ្ទះទៅជាមួយម៉ែខ្ញុំប្តីវាទៅរលស៊ីនៅស្រុកឃួនទៅទិញឥវ៉ាន់យកមកលក់បោះអ្នកលឿងចឹងហាស!

ក៖ បាទយាយ!

ខ៖ ហើយដល់នេះម៉ោងបួនម៉ោងប្រាំណុងបានមកដល់ផ្ទះម៉ោងបួនម៉ោងប្រាំយប់ហោស!

ក៖ អូ៎បាទយាយចឹងមានន័យថាយាយនៅជាមួយឪពុកម្តាយហាត់ជាងណោះយាយណោះ?

ខ៖ អើហាត់បើម៉ែតែពីរនាក់ម៉ែហ្នឹងកូនប្អូនខ្ញុំវារៀនដល់ថ្នាក់ទីដប់មួយដប់ពីរណោះវាមានមកជួយធ្វើអីណាកាលណុង។

ក៖ អូ៎បាទយាយចុះម្ហូបអីដែរយាយចូលចិត្តហូបយាយ?

ខ៖ ម៉ែខ្ញុំស្អីគាត់ចេះតែទិញទៅតិចទៅគាត់ចង់ហូបនេះដល់គាត់ទិញមកអោយស៊ីទៅបើខ្ញុំឈឺវិញអីនៅអីស្រុកពាមរហ្នឹងគាត់ទៅទិញដល់អ្នកលឿងហោសគាត់ដើរទៅទិញអត់មានរបកអត់មានម៉ូតូអីទេកាលណុង។

ក៖ អូ៎!

ខ៖ មានតែរទេះសេះប្រាំពីរប្រាំបីគីឡូដី។

ក៖ ប្រាំពីរប្រាំបីគីឡូដីហើយណោះយាយណោះឆ្ងាយ?

ខ៖ ចាំម៉ែខ្ញុំគាត់ទៅទិញដល់អ្នកលឿងហោសរួចថៅឈឺក៏ដោយ។

ក៖ អូ៎បាទចុះយាយគិតថាចឹងល្បែងប្រជាប្រិយ៍អីដែរយាយចូលចិត្តលេងយាយតាំងពីក្មេងហាសដូចលាក់កន្សែងបោះអង្គុញទាញព្រាត់នៅពេលចូលឆ្នាំអីចឹងហាសយាយ?

ខ៖ មានស្អីទេមានតែលេងអង្គុញអីហ្នឹងគេទាញព្រាត់អីហ្នឹងម៉ាជំនាន់ណុងក្មេងៗប៉ុនៗគ្នាហ្នឹង!

ក៖ អូ៎បាទយាយប៉ុន្តែកាលណុងយើងលេងនៅណាយាយ?

ខ៖ លេងនៅភូមិយើងនៅក្នុងភូមិខ្ញុំស្រុកពាមរភូមិបឹងព្រះហ្នឹង!

ក៖ ពីរនាក់បិទសំលេងបន្តិចចុះយាយគិតថាចឹងយាយចូលចិត្តរាំទេយាយ?

ខ៖ អត់ដែរ។

ក៖ តាំងពី..?

ខ៖ អត់ចូលចិត្តផង។

ក៖ តាំងពីក្មេងក៏អត់ចូលចិត្តដែរណោះយាយ?

ខ៖ ចាំខ្ញុំអត់ចេះរាំផង។

ក៖ ចុះចឹងយាយចូលចិត្តច្រៀងអត់?

ខ៖ អាច្រៀងហ្នឹងលែងចេះសោះ។

ក៖ អូ៎បាទចុះបែបល្ខោនយីកេអាយ៉ៃអីយាយចូលចិត្តអត់យាយ?

ខ៖ ល្ខោនអាយ៉ៃទៅមើល។

ក៖ យាយទៅមើលណោះយាយណោះ?

ខ៖ ចាំទៅទៅនាំប្អូនតូចៗចឹងទៅរួចចេះតែទៅអោយជូនវាទៅជាមួយទៅ។

ក៖ បាទយាយ!

ខ៖ ដល់គេឈប់លេងទៅមកផ្ទះទៅនាំគ្នាកាត់ព្រៃកាត់ភូមិមកទៅផ្ទះវិញទៅ។

ក៖ អូ៎បាទយាយចុះយាយគិតថាចឹងអើសព្វថ្ងៃធិមយាយចូលចិត្តស្ដាប់ណោះយាយណោះ?

ខ៖
ខ្ញុំទើបងងឹតភ្នែកហ្នឹងខ្ញុំមើលអត់ឃើញធិមចឹងខ្ញុំសូត្រៗខ្មោចងាប់ឈឺងាប់ប៉ុន្មាននាក់ខ្ញុំទៅសូត្រទាំងអស់ហ្នឹង។

ក៖ អូ៎!

ខ៖
ដល់ឥឡូវខ្ញុំមើលអត់អីឃើញហើយសៀវភៅគាក៏អត់យកមកធិមអីក៏ដោយដល់ខ្ញុំមើលមិនឃើញ គាត់ប្រាប់ទៅថាតាមគាត់ទៅ។

ក៖ អូ៎!

ខ៖ បើមើលអក្សរអត់ឃើញផង។

ក៖ បាទយាយ!

ខ៖
ពីដើមខ្ញុំស្ងូត្រធិមថាគេចូលចិត្តអោយសៀវភៅខ្ញុំហាសម៉ាកំណាយកខ្ញុំទុកស្ដាយសៀវភៅធិមយកមកខ្ញុំចែកអោយចាស់ៗគាត់មើលរួចគាត់មើលឃើញចឹងអោយគាត់អស់រលីង។

ក៖
បាទយាយចុះយាយគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារយាយចេះលេងឧបករណ៍ភ្លេងអត់យាយទាំងកូនចៅកូនក្មួយអីហាស?

ខ៖ អត់មានទេមានអ្នកណាទេ។

ក៖ អត់មានទេណេះ?

ខ៖ មានអាចៅមួយ។

ក៖ អ៊ូគាត់ចេះលេងអីគេពូ?

ខ៖ ចៅមិនអីណាដាប់ឈើដាប់អីព្រះហ្នឹង!

ក៖ អ៊ូបាទពូ។

ខ៖ យកពីអូរកាទៀងហោស!

ក៖ នៅអូរកាទៀងហោស?

ខ៖ បាទ!

ក៖
ចុះយាយចឹងយាយគិតថាផ្ទះរបស់យាយតាំងពីក្មេងរហូតមកដល់ឥឡូវមានលក្ខណះបែបណាយាយកាលពីក្មេងយាយនៅជាមួយឪពុកម្ដាយផ្ទះម៉េចទៅ?

ខ៖
ផ្ទះពីដើមខ្ញុំប្រកស្លឹកផ្ទះធំដែរអាធំណុងដល់អានេះប្រកស្លឹកដល់ទៅបានខ្ញុំជញ្ជាំងក្តារជញ្ជាំងដែកអាណែងរនាបក្តារ។

ក៖ អ៊ូ!

ខ៖ ប្រកក្បឿង។

ក៖ បាទយាយប៉ុន្តែដល់ពេលមកដល់ឥឡូវយាយនៅជាមួយកូនចៅ?

ខ៖ ចាំ

កៈ អ៊ូបានផ្ទះហ្នឹងនៅណោះយាយណោះ?

ខៈ អត់ទេផ្ទះហ្នឹងពុករលួយរុះទៅរុះលក់អោយគេក្បឿងអីអស់ទៅ។

កៈ អ៊ូចុះកាលយើងលក់ហ្នឹងលក់បានប៉ុន្មានទៅយាយ?

ខៈ
អូយលោកគ្រូអើយផ្ទះណុងរុះទៅផ្ទះណុងរុះទៅគ្រាន់ចេះតែទុកៗធ្វើយូរៗទៅលក់អោយ..!

កៈ អ៊ូបាទចុះចឹងយាយគិតថាយាយមានបងប្អូនកូនចៅណាដែរចេះធ្វើផ្ទះអត់យាយ?

ខៈ មានក្មេងអើខ្ញុំធ្វើផ្ទះខ្ញុំរកតែក្មួយៗចៅៗហ្នឹងនៅណុង។

កៈ អ៊ូកូនចៅណុងចេះធ្វើហោសយាយហោស?

ខៈ ចាំ!

កៈ ប៉ុន្តែកូនចៅនៅណោះអត់ចេះទេ?

ខៈ កូនចៅហ្នឹងក៏ចេះជាងអីទេកូនបើវាមិនដែរធ្វើផ្ទះធ្វើតែរបស់ឯងហ្នឹងចេះនៅ។

កៈអ៊ូ!

ខៈ ផ្ទះឯងនៅហ្នឹងធ្វើតូចៗហ្នឹងតូចនៅហ្នឹង!

កៈ ធ្វើបែបលក្ខណៈផ្ទះតូចៗហ្នឹងហោស?

ខៈ ចាំតូចៗធំៗចេះតើ!

កៈ អ៊ូបាទចុះ..?

ខៈ ចេះតៗគ្នា។

កៈ អ៊ូបាទ!

ខៈ
រឿងធ្វើហាសរោងគោរោងមាន់អីចេះតែចេះហើយហើយផ្ទះនៅខ្លួនឯងណុងចេះតែធ្វើទៅ
។

កៈ
បាទយាយចុះយាយគិតថាចឹងឪពុកម្តាយរបស់យាយកាលពីមុនគាត់ស្លាប់គាត់ធ្លាប់បង្រៀ
នពីជំនាញអីទៅយាយអត់?

ខ៖ 
មានជំនាញអីទេគាត់ថាអត់ពីគាត់ទៅអោយរកស៊ីរកអីកុំធ្វើបាបប្អូនកុំអីហ្នឹងតែប៉ុណ្ណឹងគាត់ស្លាប់គ្មានបានម៉ាម៉ោងផងគាត់ស្លាប់គាត់ក្តៅ។

ក៖ អូ៎បាទយាយចុះយាយគិតថាចឹងវេញវល្លិ៍
កូរស្កុរឡើងត្នោតធ្វើកន្ទេលអីពួកគាត់ចេះអត់ពួកគាត់ធ្លាប់បង្រៀនទៅយាយអត់?

ខ៖ ធ្វើកន្ទេលគាត់ចេះតែកន្ទេលស្លឹកត្នោត។

ក៖ អូ៎!

ខ៖ គាត់ត្បាញ។

ក៖ អាកន្ទេលចាក់ស្លឹកត្នោតហីយាយណេះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែគាត់ធ្លាប់បង្រៀនទៅយាយអត់?

ខ៖ 
ខ្ញុំចេះដែរជំនាន៉អាពតដល់ឥឡូវខ្ញុំលែងចេះទៅបើគេប្រើកន្ទេលលីងឡុងកន្ទេលអីលែងបើអាកន្ទេលស្លឹកត្នោត។

ក៖ 
អូ៎ប៉ុន្តែកាលយាយអាចប្រាប់ចៅបានទេថាពេលដែរយាយធ្វើកន្ទេលស្លឹកត្នោតហ្នឹងយាយចំណាយរយះពេលប៉ុន្មានក្នុងកន្ទេលមួយហាស ហើយធ្វើគ្នាប៉ុន្មាននាក់ទៅ?

ខ៖ ជាមួយណុងគ្នាពីរបីនាក់អីណោះ។

ក៖ យាយធ្វើបានប៉ុន្មានថ្ងៃយាយធ្វើហើយមួយយាយ?

ខ៖ បើគេអ្នកនេះខ្ញុំចេះតែត្បាញខ្ញុំអត់ចេះបត់ខ្ញុំអត់ចេះបត់មុខ។

ក៖ អូ៎ប៉ុន្តែកន្ទេលមួយយើងធ្វើឧទាហរណ៍ថាយើងធ្វើបីនាក់ចឹងពីរថ្ងៃអីហាសណេះយាយ?

ខ៖ ពីរថ្ងៃអត់ហើយទេល្មមបត់ជាយសងខាង។

ក៖ អូ៎បាទយាយប៉ុន្តែកន្ទេលជំនាន់ហ្នឹងយើងលក់មួយបានប៉ុន្មានទៅយាយ?

ខ៖ អើយ..!

ក៖ យើងទុកប្រើខ្លួនឯងតើហីយាយ?

ខ៖ ខ្ញុំមិនកន្ទេលកាលណុងមួយជាងពីរម្ភៃរៀលអីជាង។

ក៖ អូ!

ខ៖ ហើយសាមសិប។

ក៖ អូដូរហេស?

ខ៖ ចាំដូរពោតយកមកដូរពោត។

ក៖ បាទៗ!

ខ៖ ដូរពោតដូរស្រូវគេរអ្នកដែងគេស្រែលើគេក៏ដូរគ្នាអត់បាយអត់អីហ្នឹងយកទៅដូរពោត។

ក៖ បាទយាយ!

ខ៖ ធ្វើល្អីល្អីមួយល្អីមួយម៉ាៗបើពោតម៉ាល្អីហ្នឹងល្អីមួយ។

ក៖ អូម៉ាល្អីហ្នឹងស្មើរម៉ាល្អីមួយចឹងទៅ?

ខ៖ ចាំ!

ក៖ ធ្វើអោយគាត់?

ខ៖ គ្រាន់ពោតទាំងស្នូល។

ក៖ អូអាហ្នឹងគិតទាំងអាពោតមួយៗកាចទាំងស្នូលទាំងអីហ្នឹងហេស?

ខ៖ ណុងហើយ!

ក៖ អូ!

ខ៖ យើងបកចេញអាហ្នឹងយើងបកចេញអោយគេអោយស្អាតទៅ។

ក៖
អូបាទយាយចុះចឹងយាយគិតថាយាយអាចប្រាប់ចៅពីអើពីជំនាន់មួយជំនាន់បានអត់យាយដោយសារយាយកើតទាន់ជំនាន់បារាំងអត់?

ខ៖
ជំនាន់បារាំងខ្ញុំនៅតូចប្អូនខ្ញុំក៏នៅតូចដែរប៉ុនអាបារាំងហ្នឹងវាសុំប្អូនខ្ញុំថាអាម៉ែខ្ញុំគាត់ប៉ទៅផ្សារហើយថាអោយសុំទៅកាលណុងជំនាន់បារាំងណុង។

ក៖ បាទយាយ!

ខ៖ សាលាណុងក៏នៅទាល់តែឥឡូវដែរថាអាសាលាជំនាន់បារាំងណុង។

ក៖ អូ៎!

ខ៖ ជំនាន់បារាំងវារស់នៅម៉េចចង់សួរចេះ។

ក៖
ចុះបែបលក្ខណៈរស់នៅរឺមួយក៏មានទ័ពបារាំងអីគេធ្វើអាណានិគមន៍ទៅលើខ្មែរយើងណោះយាយណោះ?

ខ៖
មានអាកាលណុងបារាំងហើយយួនមានវាយួនវាធំជាងដល់យួនវាចាប់ខ្មែរយើងចឹងទៅបារាំងហ្នឹងវាទៅហៅអាយួនហ្នឹងមក អាយួនណុងមេវាក៏មេធំដែរ។

ក៖ បាទយាយ!

ខ៖ កាលណុង។

ក៖ រួចចុះអើពេលហ្នឹងបារាំងគេមានធ្វើបាបខ្មែរយើងអីអត់យាយ?

ខ៖ អត់ទេជំនាន់ណុងអត់មានទេ។

ក៖ ចុះបែបការរស់នៅវិញម៉េចទៅយាយយើងធ្វើការធម្មតាយើងរកស៊ីធម្មតាណោះយាយ?

ខ៖ រកស៊ីធម្មតា។

ក៖ អូ៎បាទចុះជំនាន់អ៊ីសារ៉ាក់វិញអ៊ីសារ៉ាក់មុនបារាំងរឺក៏ក្រោយបារាំងយាយ?

ខ៖ ជំនាន់អាបារាំងហើយបានអ៊ីសារ៉ាក់។

ក៖ អូ៎!

ខ៖ បានអ៊ីសារ៉ាក់។

ក៖ ប៉ុន្តែអ៊ីសារ៉ាក់ហ្នឹងយាយដឹងខ្លះហើយណោះយាយណោះ?

ខ៖
ដឹងហើយខ្ញុំដឹងហើយបានអីវាអាជំនាន់អ៊ីសារ៉ាក់ហ្នឹងបងប្អូនខ្ញុំក្រមុំៗស្អាតៗចឹងវាសុទ្ធតែមកចាប់មកចាប់។

ក៖ អូ៎បាទយាយ!

ខ៖ អាជំនាន់ណុង។

កៈ ចុះចឹងអើបងប្អូនយាយមានត្រូវគេចាប់ដែរអត់ទេ?

ខៈ មីងខ្ញុំត្រូវមីងខ្ញុំនៅក្នុងព្រៃកវាចាប់យកទៅជំនាន់អ៊ីសារ៉ាក់។

កៈ ពួកណាគេចាប់យកទៅយាយ?

ខៈ ពួកអ៊ីសារ៉ាក់ចាប់ទៅតែម៉ងពួកអាបារាំងជំនាន់បារាំងជំនាន់យួនណុង។

កៈ ប៉ុន្តែអ៊ីសារ៉ាក់ណុងជនជាតិអីយាយ?

ខៈ ជនជាតិខ្មែរយើងដែរហ្នឹងអាអ៊ីសារ៉ាក់ណុងមានស្អី។

កៈ អូ៎វាចាប់មនុស្សស្រីអោយយកធ្វើអី?

ខៈ វាចាប់មនុស្សស្រីយកធ្វើប្រពន្ធហាស!

កៈ អូ៎!

ខៈ
អាណាស្អាតៗគេចាប់ស្អាតៗគេចាប់ហើយចាប់ទុកអើដូចថានិយាយអោយអស់ដូចលោកគ្រូចាប់យកទៅបើនោមដាក់ក្បាលវាម៉េចក៏វាមិនទំលាក់ដៃវាលីទាល់ដល់ផ្ទះវាហ្នឹង!

កៈ អូ៎បាទសំខាន់តែវាចង់បាននរណាមួយហើយណោះ?

ខៈ ហ្នឹងហើយតែវាចង់បាននរណាហើយវាចាប់ហើយ!

កៈ
បាទយាយចុះចឹងយាយគិតថាពេលចូលជំនាន់អ៊ីសារ៉ាក់ចប់យើងចូលជំនាន់អីយាយដាបឈ្លូនយាយទាន់អត់?

ខៈ ណុងអាដាបឈ្លូនណុងហើយបានមក។

កៈ យាគកុង?

ខៈ អត់ទេបើដាបឈ្លូនសំសេរីណុងហើយបានមក។

កៈ លុនណុង?

ខៈ លុនណុលមានលុនណុលណុងជាមួយអាដែងកាលជំនាន់ណុងឪអាសំរាំស៊ីណោះ។

កៈ បាទយាយ!

ខៈ ចាំជំនាន់ណុង។

កៈ អ៊ូប៉ុន្តែជំនាន់ណុងគេធ្វើនយោបាយយើងអត់មានបញ្ហាណាហីយាយហោស?

ខៈ អត់មានបញ្ហាទេគេអត់មានធ្វើបាបអីទេកាលណុងតាំងពីឪសម្តេចហោស!

កៈ បាទយាយ!

ខៈ ជំនាន់ណុង។

កៈ អ៊ូ!

ខៈ តាំងពីឪសម្តេចតាសុគត់ទៅហ្នឹងហោស!

កៈ អ៊ូបាទយាយពេលណុងក៏សម្តេចតាគាត់នៅជួយ..?

ខៈ នៅកាលណុងគាត់នៅកាលណុងត្រលប់មកម៉ែសម្តេចសុវត្តិកោតណុងនៅ។

កៈ អ៊ូបាទចុះរហូតដល់បានចូលដល់ជំនាន់លុនណុលហីយាយណេះ?

ខៈ
ជំនាន់លុនណុលណុងខ្ញុំរត់ទៅនៅអីលើដល់វាផ្លោងដាក់ក្រោយផ្ទះហ្នឹងពេកខ្ញុំប្តីប្រពន្ធខ្ញុំដេកតែដីចឹងអាគ្រោសពីក្រោមចឹងក្រាលកន្ទេលដេកនៅដីអីទេខ្ញុំអត់ទាន់មានកូនទេ ហើយម៉ែខ្ញុំក៏គាត់នៅលើផ្ទះគាត់សុំអាបងវាមួយណុងនៅបីតែចៅជាប់ហ្នឹងដៃបញ្ចុកទឹកដោះហ្នឹង!

កៈ អ៊ូបាទយាយ!

ខៈ
ដល់វាផ្លោងពេកទៅវាមិនត្រូវអាដែងមុខផ្ទះខ្ញុំចំហៀងចឹងហោសផ្ទះពូខ្ញុំត្រូវដើមពុទ្រាបាក់ហើយត្រូវធំខ្ញុំត្រូវចំទីណោះហើយបងខ្ញុំត្រូវចំណោះវាបែកអំបែងវាបុកដើមពុទ្រាណុងហើយ..!

កៈ បាទ!

ខៈ
ដល់នេះបងយកទៅពេទ្យទាំងយប់យកកាលណុងបុកបងខ្ញុំក៏នៅធ្វើទាហ៊ានតេទៅបានយកបងធំខ្ញុំហើយហ្នឹងបងខ្ញុំទៅទាំងយប់ហ្នឹងហើយខ្ញុំពីរនាក់អាប្អូនជីដូនមួយហ្នឹងដេកតែដី។

កៈ អ៊ូ!

ខៈ វាមិនដែរបានឡើងលើផ្ទះដេកទេមិនហ៊ានឡើងខ្លាចចុះមិនទាន់។

កៈ
បាទយាយចុះចឹងអើពេលជំនាន់លុនណុលណាងមានគេបន្ទុះគ្រាប់ផ្លោងអីណោះយាយណោះ?

ខៈ អូ្យគ្រាប់ផ្លោងច្រើនហើរវាមានយួននៅក្នុងភូមិខ្ញុំហ្នឹងហាស!

កៈ បាទយាយ!

ខៈ អាទីហ្នឹងសុទ្ធតែប្រជាជនខ្មែរប្រជាជនយួនចឹងហាស!

កៈ បាទ!

ខៈ
វៀតណាមចឹងទៅដល់នេះវាផ្លោងចឹងទៅផុតៗហួសជំបូលផ្ទះខ្ញុំចឹងទៅទៅធ្លាក់នៅក្រោយណុងទាំងកណ្តាលបឹងចឹងទៅ។

កៈ អ៊ូបាទយាយ!

ខៈ ហើយក៏ទៅដល់ស្រុកចាក់ណុងងាប់គោងាប់ក្របីវាផ្លោងហាសណាស់។

កៈ
បាទយាយប៉ុន្តែអើយាយនៅផ្ទះយើងអីបងប្អូនយើងអត់មានត្រូវគ្រាប់ផ្លោងត្រូវអីណាយាយណោះ?

ខៈ អត់មានទេមានតែអាដែងខ្មៀតអំបែងត្រូវធំខ្ញុំហើយបងខ្ញុំជីដូនមួយនៅក្បែរណុង។

កៈ ប៉ុន្តែអត់ស្លាប់ណាយាយហេស?

ខៈ អត់ទេទៅដេកពេទ្យមួយខែហោស!

កៈ អ៊ូបាទចុះអើពេលណុងយាយថាគេមានត្រង់សេមានអីណោះយាយ?

ខៈ
មានត្រង់សេខ្ញុំមានអង្ករបីបួនប៉េដាក់ក្នុងត្រង់សេណុងអោយគ្រប់ទៅដែកអៀងប៉ាន់ចឹងទៅកើបដីដាក់ពីលើសង្កត់ទៅឈើអីសង្កត់ទៅមាននេះទេដេកតែត្រង់សេទេ។

កៈ អ៊ូបាទយាយ!

ខៈ អង្ករអីមិនដែរហ៊ានដាក់លើផ្ទះទេខ្លាចឡូឆេះផ្ទះអីទៅគ្មានអីស៊ី។

កៈ អើទាំងអង្ករទៅទៀត?

ខ៖ អស់អង្ករទៀត។

ក៖ អូ៎ប៉ុន្តែលឺថាយប់ហ្នឹងអើយប់ៗឡើងគេអត់បើកភ្លើងអោយយើងណាហីយាយ?

ខ៖ មានភ្លើងទេស្រុកណុងគ្មានភ្លើងទេ។

ក៖ ប៉ុន្តែភ្លើងដែរយើងបង្កាត់ភ្លើងអីយើងពន្លត់ពីមុនយប់ណោះយាយណោះ?

ខ៖
ចាំណុងដាំម្ហូបតាំងពីភ្លឺៗខ្លាចគ្រាប់ផ្លោងណុងខ្លាចពីណុងដាំម្ហូបតាំងពីម៉ោងបីម៉ោងបួនដាំឆ្អិនអស់ហើយ!

ក៖ ប៉ុន្តែថ្ងៃឡើងយើងនៅតែទៅធ្វើស្រែធ្វើចំការធម្មតាចឹង?

ខ៖ ធ្វើស្រែចំការណុងខ្ញុំស្ទូងយប់ម៉ង។

ក៖ អូ៎!

ខ៖ រួចស្ទូងយប់រួចគ្នាប៉ុន្មានក្រុមពីរក្រុមចឹងស្ទូងយប់។

ក៖ បាទយាយ!

ខ៖
ទៅចឹងទៅខ្លាចវាផ្លោងមកចឹងទៅអត់ហ៊ាន់តែមាត់ផងយើងចេះតែស្ទូងទៅយប់ហ្នឹងមើលអីមិនឃើញចេះតែដោតទៅ។

ក៖ អូ៎បាទយាយអត់ទេរវល់មួយភ្លែតសិនតិចទៀតចាំតេទៅវិញសម្ភាសមួយភ្លែត
អូ៎ចឹងចុះយាយគិតថាអើយើងធ្វើស្រែចំការធម្មតាចឹងទៅ?

ខ៖ អើ!

ក៖ លក់ដូរធម្មតាណោះយាយ?

ខ៖ ចាំលក់ដូរធម្មតាមិនអីទេ។

ក៖ អូ៎បាទយាយរួចចុះអើចឹងប៉ុន្តែយើងនៅម៉្ញុំជាមួយឪពុកម្ដាយយើងណោះយាយណោះ?

ខ៖ ខ្ញុំមានតែម្ដាយឪពុកខ្ញុំគាត់បែកគ្នាគាត់ទៅនៅស្រុកស្រែលើហោស!

ក៖ បាទ!

ខ៖ ខ្ញុំមានតែម៉ែខ្ញុំហើយប្អូនខ្ញុំម្នាក់ដែងគេយកទៅសំលាប់ដែរណុង។

កៈ
បាទយាយប៉ុន្តែយាយពេលដែរលុនណុលហ្នឹងយើងមានគ្រួសារមានកូននៅយាយយាយ
ហាស?

ខៈ ខ្ញុំកាលលុនណុលខ្ញុំទើបបួសធំអាកូនខ្ញុំពីរខែទេ។

កៈ អ៊ូប៉ុន្តែប្តីរបស់យាយនៅជាមួយយាយដែរ?

ខៈ
ប្តីខ្ញុំគេទៅនៅអីកន្លែងគេធ្វើការគេហៅដូចថាអើឥឡូវធ្វើអីៗគេហៅទៅជួយធ្វើគេចឹងហាស
!

កៈ អ៊ូបាទយាយ!

ខៈ
ចាំហើយកូនខ្ញុំនៅពោះធំក្នុងពោះណុងខ្ញុំមានទំលាក់បាញ់អាគ្រាប់បំបឹមកធ្លុះបែកខ្ទាយហែ
ងធ្លាយពេញផ្ទះពេញនេះខ្ញុំអង្គុយតែក្នុងគុម្ពប្ញស្សីម៉ងលោកគ្រូអើយ!

កៈ បាទយាយ!

ខៈ នៅក្នុងគុម្ពប្ញស្សី។

កៈ បាទយាយបាទចុះយាយគិតថាចឹងអើដល់ពេលដាច់ជំនាន់ប៉ុលពតហើយបានយើងអើ
ដាច់ជំនាន់លុនណុលហើយបានយើងចូលប៉ុលពត?

ខៈ ចូលអាពតប៉ុលពត។

កៈ អ៊ូប៉ុលពតជាពេលដែរយើងពិបាកហើយណោះយាយណោះ?

ខៈ យើងពិបាកណាស់។

កៈ ពេលប៉ុលពតហ្នឹងយាយអាយុប៉ុន្មានហើយយាយចាស់ហើយ?

ខៈ ខ្ញុំប្រហែលខ្ញុំកាលប៉ុលពតណុងខ្ញុំប្រហែលសែសិបជាងហើយ!

កៈអ៊ូយាយសែជាងហើយហោស?

ខៈ ចាំ!

កៈ ពេលណុងយាយមានកូនទាំងអស់ហើយណោះយាយណោះ?

ខ៖
មានកូនអស់ហើយកូនសុំមួយវាមួយប៉ុនអាតែអានេះទេទៅស្ទូងដកចឹងទៅម៉ោងបីម៉ោងបួនខ្ញុំឡើងដាំបាយ
ដាំបាយហើយទៅទៅទំរាំដល់កន្លែងស្ទូងណុងវាម៉ោងប្រហែលជិតប្រាំមួយអីណោះ។

ក៖ បាទយាយ!

ខ៖ ហើយប៉ក្ងនដៃម្ខាងយួរកំរេលដៃម្ខាងវេទនាណាស់។

ក៖ អូ៎បាទយាយ!

ខ៖
ហើយកូនខ្ញុំធំដែរហើយប៉ុន្តែដើរមើលវាមិនឃើញវាយប់វាងុយដេកវាខ្ញុំចេះតែប៉ក្ងនទៅទៅដល់ចឹងទៅគេអោយអង្ករមួយកំប៉ុងពីរហ្នឹងទៅខ្ញុំមនុស្សចាស់គេអោយមួយកំប៉ុងកូនខ្ញុំគេអោយកន្លះកំប៉ុងគេថាឯងស៊ីកំលាំងស្រាលតូច
ស្រាលគ្មានធ្វើអីទេស៊ីតែកន្លះកំប៉ុងយកទៅមានអាដែងនេះគេគេអោយដាំដាំហ្នឹងគេយកដល់តែពេលជួសអោយវេទនាតាំងពីជួសអោយអង្ករឯងមួយកំប៉ុងអង្ករក្ងនកន្លះកំប៉ុងហើយគេអោយបាយតែបីវែកទេ។

ក៖ បាទយាយចុះពេលហ្នឹងគេជំលាសយើងទៅណាយាយប៉ុលពត?

ខ៖ ខ្ញុំជំលាសទៅខ្ញុំរត់ទៅនៅស្រែ។

ក៖ តែនៅព្រៃវែងហ្នឹង?

ខ៖ ចា៎ស្រុកបាភ្នំ។

ក៖ អូ៎នៅខាងបាភ្នំហោស?

ខ៖ ចា៎!

ក៖ អូ៎!

ខ៖
អោយខ្ញុំបានមកវិញខ្ញុំទៅដល់ភ្នំពេញណោះខ្ញុំទៅដល់គៀនស្វាយហោសអើទៅដល់គៀនស្វាយបែកអាពតណុងយួនចូលចេញពីយើងទៅហោសចេះតែទៅៗ។

ក៖ អូ៎!

ខ៖ ជំនាន់អាពតណុងអើ..!

កៈ បាទ!

ខៈ
អាពតអត់ទាន់មកដល់ទេណុងខ្ញុំដើរទៅគេដេកនៅអីនេះណោះបីបួនយប់បានខ្ញុំដើរគេថាហោសទៅៗម៉ែសឹងធ្លាក់ពីលើផ្ទះ។

កៈ អូ៎!

ខៈ បែកមុខបែកមាត់អស់គេដេញអោយចុះទៅៗ។

កៈ បាទ!

ខៈ ហើយម៉ែខ្ញុំគាត់ខំទូលបាយទូលអង្ករទូលអាដែងកញ្ចប់អីៗទៅ។

កៈ អូ៎!

ខៈ
ហើយវាណោះវាវែកមាន់ពីរនាក់អាបងវាណុងម៉ាកន្ត្រកហ្នឹងទៅដល់វែកដាក់ទៅមុខអត់រួច។

កៈ បាទ!

ខៈ
អាណុងវាចូន់វាខឹងចេះតែយំវាដេញវាថាយួនចូលមកគ្រប់គ្រងយួនចូលមកហើយសំលាប់អស់ហើយ!

កៈ វាកៀងយើងទៅហីយាយ?

ខៈ ចាំវាកៀងទៅកៀងយកទៅសំលាប់អីចឹងទៀតហាស!

កៈ បាទៗ!

ខៈ កុំនៅអាយួនវាវះពោះច្រកស្មៅច្រកចូលទឹកទន្លេអស់ហើយ!

កៈ អូ៎!

ខៈ ខ្ញុំរត់ទាំងទៅទាំងមកអស់ជិតដប់យប់បានបានមកដល់ផ្ទះវិញ។

កៈ
បាទយាយចុះអើចឹងគេជំលាសយាយទៅតែខាងណុងអត់មានទៅណាផ្សេងទៀតទេណោះ?

ខៈ អត់ទៅខ្ញុំទៅ។

កៈ មកលើវិញ?

ខៈ
មកផ្ទះវិញលោកគ្រូមកផ្ទះវិញតាំងមកផ្ទះវិញបានអាប្អូនអាបងថ្លៃខ្ញុំណោះរែកពុនខ្ញុំអាហ្នឹង
ពីរនាក់ប្អូនវាបងវាហ្នឹងតែតិចទៀតដល់គុកទូលស្លែងស្លាប់បាត់។

កៈ អ៎ូ!

ខៈ កៀជិតដល់រណ្ដៅហើយហ្នឹងហាសខ្ញុំគេយកទៅសំលាប់ជិតដល់រណ្ដៅហើយហ្នឹង!

កៈ បាទៗ!

ខៈ កម្ម៉ង់ដូចឯងកុំទៅទៅកើតវិញទៅ។

កៈ អ៎ូ!

ខៈ អាម៉ែអើយទៅផ្ទះវិញទៅកូនមកហើយមកជួយហើយ!

កៈ បាទយាយ!

ខៈ កាលណុងឆ្នាំចិតប្រាំបួនណុង។

កៈ អ៎ូចុះយាយគិតថាចឹងរបបអាហារយើងជំនាន់ណុងម៉េចយាយ?

ខៈ គេបាយខ្ញុំស៊ីបាយរូមស៊ីបាយរូម។

កៈ អ៎ូបាទយាយ!

ខៈ
បបរគេអោយបីវែកចឹងទៅកូនខ្ញុំបើចេះកូនអាធំហ្នឹងមួយណុងវាចេះវាហែកស្លឹកចេកមករំ
ទៅ។

កៈ បាទយាយ!

ខៈ
យកទៅបបរបីកូនវែកណោះវាហូបមិនអស់វាខ្ចប់ម្នាក់ហ្នឹងមួយខ្ចប់ត្រីមួយចានគ្នាប្អូនប្រាំនា
ក់ណុងបេះត្រីប៉ុនមេដៃម្នាក់ប៉ុនចែកៗគ្នាទៅយកខ្ចប់ដាក់ហោប៉ាវមកផ្ទះទុកស៊ីថ្ងៃ។

កៈ បាទយាយអ៎ូប៉ុន្តែយើងមែនហូពបបរណាយាយហោស?

ខៈ ហូបបបរ។

កៈ បបរដែរហោស?

ខ៖ បបរហើយស្ងោរពោតកំបោរទាំងមូលទៀតហោស!

ក៖ អូ៎ចឹងយើងហូពអត់ឆ្អែតណោះយាយណោះ?

ខ៖
ហូបបានបីកូនវែកបានអីហ្នឹងឆ្អែតណាចេះហូបទៅយើងឆ្អែតដឹងទៅរកណាបើថាមិនឆ្ងាញ់គេយកទៅរៀនសូត្រ។

ក៖ អូ៎!

ខ៖ អូ៎អាសំលដើមចេកផ្កាកំប្លោកឆ្ងាញ់មិនឆ្ងាញ់គ្រូត្រកូនមានតែប៉ុណ្ណឹង!

ក៖ អូ៎បាទយាយ!

ខ៖ បាយក្ដាំងចេះស៊ីទៅហែង។

ក៖ នៅថាឆ្ងាញ់ចឹងណោះពូ?

ខ៖ នៅថាឆ្ងាញ់។

ក៖ ចុះអើចុះពេលយើងឈឺយាយ?

ខ៖ ឈឺគេអោយទៅដេកពេទ្យណាណោះស្នាកអីស្អីណោះអីអាខ្ញុំខ្ញុំញាក់ម៉ាខែកន្លះដល់តែមានប្អូនខ្ញុំប្រុសមួយនៅជាមួយប្អូនថ្លៃអាជីដូនមួយវាមកនៅជាមួយខ្ញុំវាសឹកបួសហើយវារត់មកនៅហ្នឹងខ្ញុំហ្នឹងដល់នេះគេអោយវាធ្វើអង្ករវែងអង្ករវែងអីសព្វទាំងអស់មានតែវាទេទើបចេះវែងចេះអីចេះទាំងអស់។

ក៖ អូ៎!

ខ៖
ថាមិនអោយគ្នាទៅណាទេអោយហែងនៅធ្វើតែអង្ករបានតែបួនប្រាំថ្ងៃមួយខែវាលែងអោយធ្វើវាថារដាក់អង្ករចឹងទៅតាំងយកប្អូនខ្ញុំទៅបានតែប្រាំថ្ងៃស្លាប់ថាស្រែកហៅខ្ញុំអើយស្រែកហៅវាស្រែកហៅម៉ែខ្ញុំថាម៉ែអើយម៉ែៗជួយកូនផងកូនស្លាប់ហើយទៅបានតែជួយអីបានទៅតាកំប៉ោយយកទៅគ្នាវា។

ក៖ អូ៎បាទពូ!

ខ៖ យកឆ្លងសាឡាងកាំភ្លើងយកទៅ។

ក៖ អូ៎!

ក៖
អ្នកអត់អីហ្នឹងយកដាក់ជាងមួយរយម៉ែត្រហ្នឹងដល់នេះទៅដកស្នុកកាំភ្លើងទៅងាប់ដាក់នេះ។

ក៖ អូ៎បាទ!

ខ៖ ងាប់ណុងអាវាដកឈ្នុកកាណូតណុង។

ក៖ អូ៎!

ខ៖
ហើយដល់នេះកាលណុងវេទនាគ្មានអ្នកណាវេទនាក្នុងសហករគេគេមានប្រហុកផ្អកគេមានសព្វទាំងអស់ប៉ុនអាទៅដល់គេអត់អោយយើងស៊ីទេ
គេអត់អោយយើងស៊ីទេគេយកដាក់រួម។

ក៖ គេយកដាក់រួមហោស?

ខ៖ ហើយអាដំឡូងនិយាយពីប្ដីខ្ញុំដាំៗរាប់រយសឹងថាតោនហោសពេញ..។

ក៖ ប៉ុន្តែគេអត់អោយយើងហូបទេ?

ខ៖ គេអត់អោយហូបទេ។

ក៖ តែដាក់រួមជាសហករ?

ខ៖
ណុងហើយអំពៅគ្រាន់តែអំពៅខ្មៅថាដាំទុកអោយកូនស៊ីថាពីរបីជួរចឹងទៅក៏គេកាប់គេថាអំពៅគេដែរ ចេកក៏ចេកគេចេកខ្ញុំពេញដីយប់ឡើងវាមកស៊ើបការ។

ក៖ អូបាទ!

ខ៖ ស្បែកជើងកង់ឡានគេណុងឆ្កែធ្វើក្រចក។

ក៖ អូ៎!

ខ៖ លោកគ្រូឯងតែវាឃើញភ្លើងស្នែកវាយកទៅបាញ់ចោលហើយ!

ក៖ អូ៎!

ខ៖
ហើយយប់ហោសគ្រាន់យើងនិយាយអីចឹងទៅយើងអុជចង្កៀងអាប្រេងហ្នឹងហាសបានច

ង្កៀងប៉ុណ្ណឹងអុជចង្កៀងវាភ្លឺហោសខ្ញុំចេះតែឆ្ងូកមើលហាសចឹងទៅឃើញមនុស្សនៅអង្គុយចាំស្តាប់ខ្ញុំគ្រប់កែងសសរទាំងអស់។

ក៖ អូ៎បាទ!

ខ៖ វេទនាហាស!

កៈ ចឹងយើងអត់ហ៊ាននិយាយអីទេណោះ?

ខ៖ យើងនិយាយអីតែនិយាយគេចាប់យកទៅតែនិយាយស្អែកគេចាប់យកទៅ។

ក៖ អូ៎!

ខ៖
ស្អែកគេហៅទៅហើយហើយមានអីណាខ្ញុំកាលណុងតែបីនាក់ខ្លាចឯងនិយាយពីអាពតពីអីរាល់ថ្ងៃមានណាមានអីទេវាងាប់មុនខ្ញុំទៀតណុងវាអាអ្នកយកការ។

ក៖ អូ៎បាទយាយ!

ខ៖ អើពិបាកដើរជាន់តែខ្មោច។

ក៖ អូ៎បាទពូ!

ខ៖
ហើយរត់ទៅនៅអីគេយកទៅដាក់រណ្តៅគេយកទៅដាក់រណ្តៅកូនខ្ញុំពីរនាក់ហើយម៉ែខ្ញុំម្នាក់ហើយខ្ញុំមកបួននាក់ហើយឆ្លងសាឡាងទំរាំយូនគេចម្លងគេយកអាពូកនារតីពូកអារជើនយកថ្នាំយកមកចាក់ទាំងឡានចាក់ចោល។

ក៖ អូ៎បាទយាយ!

ខ៖ ចាំយកមកចាក់ចោលដល់នេះខ្ញុំស្គាល់ថ្នាំ ខ្ញុំស្គាល់ថ្នាំខ្ញុំចេះតែដើររើសថ្នាំ។

ក៖ បាទ!

ខ៖
ដើរពីនេះទៅច្រកចង់អាប្អូនខ្ញុំមួយម៉ែខ្ញុំក៏មិនហ៊ានដើរចោលបានទេដល់តែនេះខ្ញុំចេះតែរើសៗខ្ញុំដឹងថ្នាំដើរយកមកដល់ខ្ញុំកើតកញ្ច្រិលទាំងពីរ។

ក៖ អើ!

ខ៖
កើតកញ្ច្រិលទាំងពីរអានេះកើតក្រោយអ៊ូអាខ្លះកើតកញ្ច្រិលខ្លះទៅបោះចោលកណ្ដាលព្រៃ
។

ក៖ អោយស្លាប់កណ្ដាលព្រៃចឹងហាសណោះពូណោះ?

ខ៖
ហ្នឹងហើយគ្មានគ្មាននរណាព្យាបាលបើវាលាប់ចឹងទៅលាប់គ្រាន់យកពីហ្នឹងទៅធ្វើរប្រហែល
ផ្ទះណុងផ្ទះណោះ។

ក៖ បាទ!

ខ៖ ហូរឈាមតាមបាត។

ក៖ អ៊ូ!

ខ៖ ណុងកូនខ្ញុំអាធំមួយហោស។

ក៖ អ៊ូបាទយាយ!

ខ៖ ឡើងខ្មៅប្រវែងណោះខ្មៅយើងហ្នឹងខ្មៅចុះ។

ក៖ បាទ!

ខ៖
ហើយខ្ញុំរលើសបានចឹងទៅខ្ញុំអោយវាផឹកថ្នាំក្ដៅថ្នាំកញ្ច្រិលអីខ្ញុំចេះតែអោយផឹកជាកូនខ្ញុំទាំ
ងពីរ។

ក៖ អ៊ូ!

ខ៖ នៅទេននោងទឹកដូង
ទឹកដូងនោងអាណុងវាលាប់មកពីមីងវាយាយវានៅក្បែរណុងថាចេះនិយាយមីមូលៗគ្រាន់
អាមួយណុងបានផឹក។

ក៖ សម្ភាសចប់ឥឡូវហើយ!

ខ៖ អាធំណុងផឹកផឹកអាណុងខ្លាំងតែអាបងអាពូវានៅជាមួយហ្នឹងក៏កើតទៀត។

ក៖ ចុះចឹងយាយគិតថាជំនាន់ប៉ុលពតយាយតាគេអោយទៅណាយាយប្ដីរបស់យាយ?

ខ៖ ប្ដីខ្ញុំជំនាន់ប៉ុលពតណុងគេអោយទៅគេអោយនេសាទ។

កៈ គេអោយនេសាទហោស?

ខៈ វាអោយទៅធ្វើការ។

កៈ ប៉ុន្តែអើនៅឆ្ងាយពីយាយណេះយាយ?

ខៈ ឆ្ងាយឆ្ងាយដែរប្រហែលសែសិបគីឡូ។

កៈ ប៉ុន្តែនៅក្នុងខេត្តព្រៃវែងដូចគ្នា?

ខៈ ខេត្តព្រៃវែងដូចគ្នា។

កៈ អូ៎!

ខៈ ខេត្តនៅជិតអ្នកលឿងតើត្រូវអ្នកជិតសាមសិបគីឡូ។

កៈ ចឹងសូម្បីតែកូនក៏អត់នៅក្បែរដែរ?

ខៈ
អត់ទេអត់មានទេឃើញកូនមកម្តងៗឃើញកូនហ្នឹងអរណោះប៉ុនគេមានហ៊ាននៅកាន់កូនទេទៅទៀតហើយ!

កៈ អូ៎ចុះប៉ុន្មានខែគេអោយនៅជួបជុំប្តីប្រពន្ធកូនចៅម្តងយាយ?

ខៈ មានជូនទៅវាសុំគេរកបន្លែរឺរកជំឡូងរឺរកស្អីទៅបានមួយភ្លេតមកមួយភ្លេតទៅ។

កៈ អូ៎!

ខៈ បើថាមិនបានគេមិនអោយយើងទេមិនហ៊ានសុំទេអត់បានទេ។

កៈ អូ៎បាទយាយ!

ខៈ អោយតែមកប៉កូនដើរចុះដើរឡើងបានតែមួយភ្លេតហ្នឹងកូនខ្ញុំអាយុទើបបីឆ្នាំហ្នឹង!

កៈ បាទចុះចឹងយាយគិតថាអើពេលដែរចូលដាច់ប៉ុលពតហើយយាយ?

ខៈ ចាំ!

កៈ ពេលហ្នឹងយើងមានការលំបាកអីទៅយាយ?

ខៈ លំបាកដែរ។

កៈ ដោយសារពេលណុងយើងអត់ទាន់មានស្រែមានចំការទេណោះយាយ?

ខ៖
មានស្រែគេអត់ទាន់ចែកផងមានអីណុងដើរមានស្អីដើរទិញជំឡូងដល់ឈើកាច់អីយកមក ស្ងោរអោយចៅអីហូបទៅ។

ក៖ អូ៎បាទយាយ!

ខ៖
ជំឡូងណោះគេមានទាន់មានអាណាអើនេះបានវាស៊ីរបស់ឯងអស់ទៅគ្រាន់តែខ្ញុំទៅធ្វើការ ម៉ោងប្រាំម៉ោងប្រាំមួយចេញម៉ោងប្រាំពីរអត់ទាន់ដល់ផ្ទះវិញទេទាល់មានស្អីៗដូចស្អាកដូច ផ្ទះក្បឿងខ្ញុំខ្ពស់ដែរហាសយកស៊ីគ្មានសល់អីទេ។

ក៖ អូ៎បាទចុះពេលណុងបើយើងអត់ទាន់មានស្រែចឹងយើងធ្វើអីយាយ?

ខ៖ វាទិញត្រីទិញអីគេយកមកផ្អកធ្វើប្រហុកយកដូរស្រែលើហោស!

ក៖ អូ៎បាទ!

ខ៖ រួចទៅផ្ញើរនេះគេកញ្ចប់អោយទៅគេអោយមួយតៅមួយថាំងមកកិនអង្ករយកមកទៅ។

ក៖ អូ៎!

ខ៖
វាកាលណុងមិនទាន់មានម៉ាស៊ីនទៀតលោកគ្រូអើយមានអីគេមានត្បាល់កិនចឹងកិនទៅយ កមកជាន់ទៅ។

ក៖ អូ៎វេទនាហាសយាយកាលណុង?

ខ៖
វេទនាថាអើវេទនាគ្រួសារខ្ញុំអត់មានកូនមានចៅណាធំមានតែពីរនាក់ម៉ែហើយកូនចាស់ៗខ្ញុំ ហៅម៉ែខ្ញុំ។

ក៖ បាទយាយរួចចុះអើដល់ពេលដែរយើងពេលណាយើងចាប់ផ្តើមធ្វើស្រែធ្វើចំការយាយ?

ខ៖ ដល់ស្រែចំការហ្នឹងវាដាក់ចាត់ជាក្រុមចាត់ជាក្រុមតាមភូមិ។

ក៖ បាទយាយ!

ខ៖ ចាត់ជាក្រុមតាមភូមិកុំអោយវាចែកចែកចឹងដូចខ្ញុំចឹងវាអោយពីរម៉ែត្រ។

ក៖ អូ៎!

ខ៖ ចឹងទៅហើយម៉ែខ្ញុំពីរម៉ែត្រចឹង។

ក៖ អ៎ូបាទ!

ខ៖
កូនខ្ញុំពីរនាក់ម៉ែហែងអត់ទាន់មានចេះមើលគោមើលក្របីអីទេគេស៊ីមួយម៉ែត្របានហើយ!

ក៖ បាទយាយពេលហ្នឹងយើងចាប់ផ្តើមធ្វើហាសណេះយាយណេះ?

ខ៖
ចាំហើយបានចែកទៅធ្វើគ្នានអីកាប់ហ្នឹងបចទេមានគោមានក្របីដែរគេអ្នកម្ចាស់ប្រធានភូមិប្រធានក្រុមអីណុងអាណុងគេមានគោមានក្របីគេភ្ជួរទៅឯងគ្មានអាណាភ្ជួរកាប់ទាំងចបជាមួយម៉ែខ្ញុំកាប់ទាំងចបណុង។

ក៖ អ៎ូ!

ខ៖ វេទនាណាស់លោកគ្រូអើយ!

ក៖ ចុះពេលណុងគេចាប់ផ្តើមចាយលុយនៅយាយដាច់ប៉ុលពតហើយហ្នឹង?

ខ៖ ដាច់ប៉ុលពតហើយដល់ភ្លាមគេអត់ទាន់មានចាយមានលុយណាចាយ។

ក៖
អ៎ូប៉ុន្តែពេលហ្នឹងអើយាយនៅប៉ុន្មាននាក់យាយពេលដាច់ប៉ុលពតហើយយាយនៅប៉ុន្មាននាក់?

ខ៖ នៅតែបីនាក់កូនខ្ញុំមួយវានៅតូចអាសុំគេមួយហើយខ្ញុំ។

ក៖ ចង់និយាយថាប្តី..?

ខ៖ ម៉ែខ្ញុំ។

ក៖ ប្តីរបស់យាយហើយហ្នឹងឪពុកគេសំលាប់ចោលហើយ?

ខ៖ ប្តីខ្ញុំគេសំលាប់ចោលអស់ហើយ!

ក៖ ម្តាយរបស់យាយនៅទេ?

ខ៖ ម្តាយខ្ញុំណុងបែកមកពីរត់វិញទៅថាទៅភ្នំពេញយកដាក់រណ្តៅណុង។

ក៖ បាទ!

ខ៖ មកវិញបានប្រហែលជាមួយខែគាត់ឈឺគាត់ស្លាប់ទៅគាត់ចេះតែក្តៅ។

កៈ អ៎ូអត់បាន...?

ខៈ ចា៎!

កៈ
អ៎ូបាទយាយចុះយាយគិតថាអើជំនាន់ណាដែរយើងចាប់ផ្ដើមសប្បាយយាយឆ្នាំកៅជាងរឺមួយក៏ម៉េចយាយមានអារម្មណ៍ថាយើងលែងភ័យថាអស់សង្គ្រាមអស់អីចឹងហាស?

ខៈ អស់សង្គ្រាមហ្នឹងឆ្នាំកៅសិប។

កៈ កៅសិបបីហេសយាយ?

ខៈ ឆ្នាំកៅសិបបីហ្នឹងអាឥឡូវហ្នឹង!

កៈ ឆ្នាំឧន្តាក់គេចូលមក?

ខៈ ឧន្តាក់ហ្នឹងណុងគេជិតដល់បោះឆ្នោតទៅណុង។

កៈ អ៎ូដោយសារពេលហ្នឹងអើសម្ដេចព្រះសីហនុគាត់បាន..?

ខៈ អើ!

កៈ យកឯករាជ្យមកវិញបានណោះយាយណោះ?

ខៈ
ចា៎យកមកបានប៉ុន្តែយកហ្នឹងហាសសម្ដេចហ្នឹងកាលគាត់រត់រយចមកហ្នឹងបានហ៊ុនសែនទៅយកដែរ។

កៈ អ៎ូ!

ខៈ
បានអីហ៊ុនសែនគាត់ទៅយកសម្ដេចសីហនុហ្នឹងគេដាក់នៅណោះកំពូលអីណាណោះហើយបានហ៊ុនសែនបានសោយរាជ្យហើយចូលមកនៅដល់ភ្នំពេញហើយគាតទៅៗដល់ពេលយកបានសម្ដេចតាហ្នឹងមកតើ!

កៈ អ៎ូបាទយាយ!

ខៈ
ហើយខ្ញុំមួយយប់ៗនាំគ្នាអូយទៅមើលដៃរទូរសទស្សន៍ឯងគ្មានទូរទស្សន៍ហ្នឹងទៅមើលអាដែងគេបើកហើយមើលតាមមើលសម្ដេចមើលហ៊ុនសែនណុង។

ក៖ អ៊ូម៉ាជំនាន់ណុងអត់មានទូរទស្សន៍មើលម៉ាភូមិមានមួយពីរអីទេណោះ?

ខ៖ ម៉ាភូមិមានមួយណុងមានអីគេយកលុយម្នាក់ពីររយទៀតហាសទិញសាំង។

ក៖ អ៊ូ!

ខ៖ ទិញប្រេងហាស!

ក៖ បាទយាយដល់ពេលចឹងយើងអត់ដែរមានអីមើលយើងទៅហាសណោះយាយណោះ?

ខ៖ ចេះតែទៅហើយ!

ក៖
អ៊ូចុះពេលណាដែរយើងចាប់ផ្តើមថាយើងរៀងធូរជាងមុនហើយណោះយាយហើយយើងរៀងចាប់ផ្តើមមានលុយមានស្រែអីមានអីគ្រប់សព្វហាស?

ខ៖ អាហ្នឹងគេបែកចិតប៉ុន្មានទេណោះចិតប្រាំបួនចឹងហើយ!

ក៖ បាទយាយ!

ខ៖
ចិតប្រាំបីចិតប្រាំបួនដឹងចិតគត់ដឹងបានចាយលុយបានអីយើងមកផ្ទះយើងមានដីរបស់យើងទៅដាំដំណាំបានលក់ដូរហើយ!

ក៖ ដោយសារបែកដំបូងយើងនៅដូរអង្ករដូរអីនៅឡើយតើហីយាយ?

ខ៖ ដូរអង្ករ។

ក៖ ដូរស្រូវ?

ខ៖ ដូរសព្វទាំងអស់ហ្នឹងដូរអង្ករហ្នឹង!

ក៖ ប៉ុន្តែគេចាប់ផ្តើមចាយលុយនៅឆ្នាំណាយាយ?

ខ៖ ដឹងឆ្នាំណាទេភ្លេចហើយ!

ក៖ អ៊ូចឹងយើងមានន័យថាយើងទាល់តែគេចាប់ផ្តើមបែកហើយយើងមកធ្វើរកតា?

ខ៖
បែកហើយចាយលុយតែម៉ងហ្នឹងខ្ញុំមកភូមិខ្ញុំបើអីបើបែកអីណោះយួនវានៅណុងវារកត្រីបើយើងមិនមានលុយម៉េចបានលុយណាហ្វប។

ក៖ អ៊ូយើងទៅទិញហោស?

ខ៖ ទៅទិញគេ។

ក៖
អ៊ូចុះយាយសុំសួរបកក្រោយបន្តិចទាក់ទងពីអាពេលដាច់ប៉ុលេះតថ្មីៗហាសពេលហ្នឹងអើខាងយួនវៀតណាមគេប្រាប់យើងថាម៉េចបានយើងអាចចេញមកបានបែកហោសចាប់ផ្ដើមហោសយាយ?

ខ៖ វាអត់ដឹងដែរ។

ក៖ ចុះយាយម៉េចបានដឹងថាបែកទៅយាយ?

ខ៖ ពេលណុងបែកហ្នឹងបែកខ្ញុំទៅដល់ជិតដល់ភ្នំពេញណុងបែកវាអត់ខ្ញុំមកផ្ទះម៉ង។

ក៖ អ៊ូយាយអត់ដឹងថាបែកទេចឹង?

ខ៖
ចាំអត់ដឹងថាបែកទេគេប្រាប់ថាម៉ែអើយយាយអើយពុកអើយពុកម៉ែអើយទៅផ្ទះកូនមកហើយកូនមកជួយហើយ!

ក៖ អ៊ូ!

ខ៖ នាំគ្នាដើរមកតែម៉ងតាំងពីភ្នំពេញមកដេកត្រឹមអ្នកលឿងទៅអីលិចហ្នឹងយប់ទៅ។

ក៖ បាទយាយ!

ខ៖ អ៊ូដើរដេកច្រើនណាស់ខ្ញុំខ្ញុំដេកត្រងគគីធំណោះបីបួនយប់ទៅ។

ក៖
បាទចឹងអើរហូតមកដល់ជីវភាពឥឡូវបានយាយចាប់ផ្ដើមធូរឥឡូវយាយចាប់ផ្ដើមនៅជាមួយកូនទៅស្រួលណោះយាយណោះ?

ខ៖ ចាំ!

ក៖ អត់បានធ្វើអីដោយសារយាយចាស់ហើយណោះយាយណោះ?

ខ៖ ចាំ!

ក៖ ប៉ុន្តែយាយឥឡូវនៅឯងឹតភ្នែកណោះយាយ?

ខ៖ ឯងដឹតអើយសព្វថ្ងៃវាគួបផ្សំថ្នាំមួយខែៗមិនដឹងជាអស់ប៉ុន្មានទេកាលមុនខ្ញុំផឹកទិញថ្នាំផ្ទះលោកគ្រូហោស!

ក៖ បាទយាយ!

ខ៖ មកទិញចឹងទៅជិតមួយខែទៅពីរខែមើលទៅវាមិនធូរថយ។

ក៖ បាទយាយ!

ខ៖ ដល់នេះទៅដេកពេទ្យចេះតែដេកពេទ្យទៅ។

ក៖ អូ៎!

ខ៖ ដល់ចេញពីពេទ្យទៅមើលទៅមិនដឹងទៅណាៗខ្ញុំទៅផ្ទះណុងដដែលណុងខ្ញុំទៅទិញថ្នាំផ្ទះលោកគ្រូដដែរទៅ។

ក៖ បាទយាយអូ៎ប៉ុន្តែគ្រាន់ថាឥឡូវយើងបញ្ហារបស់យើងគឺគ្រាន់តែយើងឈឺច្រើនទេណេះយាយណេះ?

ខ៖ ចា៎!

ក៖ តែបើថាធ្វើអីយាយនៅ...?

ខ៖ ចា៎!

ក៖ ផ្ទះចឹងទៅអូ៎ប៉ុន្តែកូនរបស់យាយអីគាត់នៅជាមួយយាយនៅផ្ទះហ្នឹងមានប៉ុន្មានគ្រួសារយាយនៅជាមួយ?

ខ៖ ផ្ទះខ្ញុំហ្នឹងហេស?

ក៖ ផ្ទះហ្នឹងបាទយាយ!

ខ៖ មានតែប៉ុណ្ណឹងគ្នាពីរនាក់ប្តីប្រពន្ធវាហ្នឹងហើយចៅអាចៅមួយថ្នាក់ទីប្រាំពីរណុងហើយខ្ញុំហ្នឹងតែបួននាក់។

ក៖ អូ៎ចឹងនៅតែបីបួននាក់ហ្នឹងទេហោសយាយ?

ខ៖ ចាំ!

ក៖
អ៊ូបាទយាយបាទចុះយាយគិតថាកាលយាយនៅរៀនហាសយាយធ្លាប់មានគោលបំណង
ថាធំឡើងយាយចង់ធ្វើអីមួយអត់យាយយាយធ្លាប់គិតអត់?

ខ៖
គោលបំណង់រៀនអីកាលណុងមានគិតអីដែររៀនអក្ខរៈកម្មណុងដូចថារៀនអោយចេះដឹង
មែនរៀនសាលាអីណារៀនអក្ខរៈកម្មរៀនតាមភូមិហ្នឹង!

ក៖ អ៊ូប៉ុន្តែយាយធ្លាប់គិតថាយាយធំឡើងយាយចង់ធ្វើប៉ូលីស
ធ្វើទាហ៊ានធ្វើអីមានធ្វើពេទ្យធ្វើអីយាយធ្លាប់គិតអត់?

ខ៖ អត់ទេ។

ក៖ អត់ដែរគិតទេណោះ?

ខ៖ ចាំ!

ក៖ ដោយសារយើងគិតថាយើងអត់មានលទ្ធភាពរឺក៏ម៉េច?

ខ៖ លទ្ធភាពមានម៉ែមានឪអីណាមានឪអីណាមានតែម៉ែ។

ក៖ អ៊ូ!

ខ៖ រកស៊ីតែពីរនាក់ម៉ែចិញ្ចឹមកូនណុង។

ក៖
បាទយាយចុះយាយបើសិនជាចៅចង់សួរសំនួរចុងក្រោយមួយហាសយាយចង់សួរថាបើសិ
នជាចង់អោយយាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយរបស់យាយចឹងហាស
យាយមានអីចង់ផ្តែផ្តាំទៅពួកគាត់អត់យាយ ទាំងកូនទាំងចៅៗអីចឹងហាសណាស់?

ខ៖
ផ្តាំទៅចង់ជំនាន់ក្រោយណុងចៅៗទាំងអស់ហ្នឹងកុំខ្ញុំពិបាកណាស់កុំប្រាប់ចៅៗជំនាន់ក្រោ
យស្រណុកហើយធូរធារហើយគ្រាន់បើមិនដូចខ្ញុំវេទនាតាំងពីតូចរហូតដល់ធំមានប្តីនៅពិ
បាក។

ក៖ អ៊ូបាទយាយ!

ខ៖ ប្តីខ្ញុំហាសពួននៅតែក្នុងផ្ទះហើយក្នុងព្រៃទេហ៎យក្នុងពោតគេដេញចាប់ធ្វើទាហ៊ាន។

កៈ អ៊ូចឹងហោសយាយ!

ខៈ ដេកតែក្នុងព្រៃម៉ង។

កៈ បាទ!

ខៈ មិនបានឡើងដេកលើផ្ទះហ្នឹងគេទេខ្លាចគេចាប់។

កៈ អ៊ូបាទយាយចុះចឹងអើយាយគិតថាចង់ផ្ដាំកូនចង់អោយកូនខំប្រឹងរៀនកូនចៅអី?

ខៈ អោយប្រឹងរៀនប្រឹងសូត្រហ្នឹងអោយកូនចៅរៀនវា..។

កៈ ដើម្បីអោយគាត់មានអនាគត់ល្អចឹងហាសណោះយាយ?
ខៈ អោយមានអនាគត់ល្អកុំអោយខ្ញុំវេទនាណាស់។

កៈ ដោយសារយើងយើងអត់ចេះចឹងយើង...?

ខៈ ចា៎!

កៈ
អត់ដូចក្មេងជំនាន់ក្រោយចុះយាយគិតថាយាយធ្លាប់ទូន្មានព្រានប្រដៅទាក់ទងពីកុំអោយពួកគាត់សេពគ្រឿងញៀនរឺមួយក៏...?

ខៈ អ៊ូប្រដៅចៅខ្ញុំទាំងអស់ខ្ញុំប្រដៅថាកូនអើយកុំផឹកគ្រឿងញៀនកូនខំរៀនខំសូត្រ។

កៈ បាទយាយ!

ខៈ
ចា៎ប្រាប់ហើយប៉ុនឥឡូវកូនខ្ញុំវាមានប្រពន្ធអស់ហើយចៅខ្ញុំវានៅតែអាទីប្រាំពីរមួយណុងហោសតូចជាងគេអាណុងអាយុប្រាំប្រាំមួយដប់បីដប់បួនហើយ!

កៈ បាទយាយបាទចឹងយាយមានអីដើម្បីចង់ប្រាប់ទៀតអត់យាយ?

ខៈ ប្រាប់អី។

កៈ យាយមានអីផ្ដែផ្ដាំទៅកូនចៅទៀតអត់?

ខៈមានអីផ្សេងទេខ្ញុំភ្លេចអស់ហើយ។

កៈ អ៊ូបាទយាយអត់អីទេយាយចឹងចៅចុងក្រោយចៅអរគុណច្រើនយាយ?
ខៈ ចា៎!
កៈ ដែរបានអោយចៅពិភាក្សាជាមួយយាយលេង?

ខ៖ ចាំ!

ក៖ ទាក់ទងពីប្រវត្តិរបស់យាយ?

ខ៖ ចាំ!

ក៖ ហើយចៅហ្នឹងដាក់ការសម្ភាសដែរយាយបានជជែកជាមួយចៅទាំងអស់ហ្នឹង?

ខ៖ ចាំ!

ក៖ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយរបស់យាយ?

ខ៖ ចាំ!

ក៖ ជាពិសេសចៅរបស់យាយបានដឹងចឹងហាសយាយ?

ខ៖ ចាំ!

ក៖
ចឹងចុងក្រោយចៅសុំការអនុញ្ញាតិពីយាយដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយរបស់សាលាពួកយើងបានទេយាយ?

ខ៖ ចឹងលោកគ្រូ។

ក៖
ចង់និយាយថាចៅអាចសុំការអនុញ្ញាតិពីយាយដើម្បីដាក់អ្វីដែរយាយនិយាយហ្នឹងដាក់ទៅក្នុងវេបសាយសាលាបានទេយាយអត់មានបញ្ហាអីណេះយាយណេះ?

ខ៖ ចាំ!

ក៖ អត់អីទេណេះយាយណេះ?

ខ៖ ចាំ!

ក៖ អ៎ូបាទយាយបាទចឹងអរគុណច្រើនណាស់យាយណា។